# លើផ្ទៃសមុទ្រនៃទ្វីបអាហ្វ្រិក
# ការជួញដូរកម្មករនេសាទកម្ពុជានៅក្នុងប្រទេស អាហ្វ្រិកខាងត្បូង

## របាយការណ៍សង្ខេប

**Rebecca Surtees**
**វិទ្យាស្ថាន NEXUS**
**ឆ្នាំ ២០១៤**

កិច្ចសហប្រតិបត្តិការស្រាវជ្រាវរវាងវិទ្យាស្ថាន NEXUS និងអង្គការ IOM

ឯកសារនេះគឺជាផ្នែកមួយក្នុងចំណោមការសិក្សាស្រាវជ្រាវរបស់វិទ្យាស្ថាន NEXUS និងគម្រោងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរបស់អង្គការ IOM ។ របាយការណ៍នេះទទួលបានការឧបត្ថម្ភគាំទ្រឲ្យបោះពុម្ពផ្សាយពីក្រសួងការបរទេសសហរដ្ឋអាមេរិក លេខ S-SGTIP-GR-0070 ។ គំនិតដែលបានលើកបង្ហាញនៅក្នុងឯកសារនេះជាទស្សនៈរបស់ស្មេរផ្ទាល់ ដោយមិនបានឆ្លុះបញ្ចាំងពីទស្សនៈរបស់ក្រសួងការបរទេសសហរដ្ឋអាមេរិក និងអង្គការអន្តរជាតិទេសន្តរប្រវេសន៍ឡើយ ។

ការតាក់តែង និងរូបភាពផ្សេងៗដែលបានបង្ហាញក្នុងរបាយការណ៍ទាំងមូលនេះមិនបានបញ្ជាក់នូវការយល់ឃើញផ្សេងៗនៅក្នុងផ្នែកណាមួយរបស់អង្គការ IOM ទាក់ទងនឹងទិដ្ឋភាពច្បាប់នៃប្រទេស ដែនសមត្ថកិច្ច ទីក្រុង ឬតំបន់ ឬសមត្ថកិច្ចរបស់អាជ្ញាធរ ឬទាក់ទងនឹងព្រំដែន និងខណ្ឌសីម៉ារបស់ប្រទេសណាមួយឡើយ ។

រូបថតដែលបានប្រើប្រាស់នៅក្នុងរបាយការណ៍នេះ គឺមិនមែនជារបស់ជនរងគ្រោះដោយសារអំពើជួញដូរមនុស្ស ឬនៅក្នុងស្ថានភាពជួញដូរនោះទេ ។ រូបថតនេះត្រូវបានប្រើប្រាស់ ដើម្បីបង្ហាញឲ្យឃើញអំពីទ្រង់ទ្រាយនានានៃឧស្សាហកម្មនេសាទទូទៅ ក៏ដូចជាស្ថានភាពផ្សេងៗដែលកម្មករនេសាទដែលគេជួញដូរអាចជួបប្រទះអំឡុងពេលទទួលរងកេងប្រវ័ញ្ច ។ រូបថតទាំងនេះក៏ត្រូវបានប្រើប្រាស់ដើម្បីឆ្លុះបញ្ចាំងពីជីវិត និងការងារនៅក្នុងប្រទេសកម្ពុជា និងអាហ្វ្រិកខាងត្បូងផងដែរ ។

អង្គការអន្តរជាតិទេសន្តរប្រវេសន៍ប្តេជ្ញាចិត្តគោរព និងអនុវត្តតាមគោលការណ៍ប្រកបដោយ មនុស្សធម៌ ដែលការធ្វើទេសន្តរប្រវេសន៍រៀបរយផ្តល់អត្ថប្រយោជន៍ដល់ជនទេសន្តរប្រវេសន៍ខ្លួនឯងផង និងសង្គមជាតិផង ។ ក្នុងនាមអង្គការអន្តររដ្ឋាភិបាលមួយអង្គការ IOM ធ្វើការជាមួយដៃគូរបស់ខ្លួននៅក្នុងសហគមន៍អន្តរជាតិ ដើម្បីជួយធ្វើឲ្យសម្រេចនូវកិច្ចខិតខំប្រឹងប្រែងប្រតិបត្តិការការងារទេសន្តរប្រវេសន៍ បង្កើនការយល់ដឹងបន្ថែមអំពីបញ្ហាទេសន្តរប្រវេសន៍ ដើម្បីជម្រុញឲ្យមានការអភិវឌ្ឍន៍ សេដ្ឋកិច្ច និងសង្គមកិច្ចតាមរយៈការធ្វើទេសន្តរប្រវេសន៍ និងជម្រុញឲ្យមានការគោរពសេចក្តីថ្លៃថ្នូរ និងសុខុមាលភាពនៃជនទេសន្តរប្រវេសន៍ ។

អត្ថបទបោះពុម្ពផ្សាយនេះត្រូវបានរៀបរៀងឡើង ដោយមិនមានការផ្ទៀងផ្ទាត់ជាផ្លូវការណាមួយពីអង្គការអន្តរជាតិទេសន្តរប្រវេសន៍ឡើយ ។

អ្នកបោះពុម្ពផ្សាយៈ អង្គការអន្តរជាតិទេសន្តរប្រវេសន៍
អគារលេខ១៧ ផ្លូវdes Morillons
១២១១ ទីក្រុងហ្សឺណែវ ១៩
ប្រទេសស្វីស
ទូរស័ព្ទលេខ: +41.22.717 91 11
ទូរសារលេខ: +41.22.798 61 50
អ៊ីម៉ែល: hq@iom.int
គេហទំព័រ: http://www.iom.int

វិទ្យាស្ថាន NEXUS
អគារលេខ 1701 ផ្លូវ Pennsylvania N.W. Suite 300
ទីក្រុងវ៉ាស៊ីនតោន ឌីស៊ី 20006
សហរដ្ឋអាមេរិក
អ៊ីម៉ែល: office@NEXUSInstitute.net
គេហទំព័រ: www.NEXUSInstitute.net

© 2013 អង្គការអន្តរជាតិទេសន្តរប្រវេសន៍ (IOM) និងវិទ្យាស្ថាន NEXUS

រក្សាសិទ្ធិ។ មិនមានផ្នែកណាមួយនៃអត្ថបទបោះពុម្ពផ្សាយនេះ អាចនឹងត្រូវផលិតឡើងវិញ រក្សាទុកនៅក្នុងប្រព័ន្ធដែលអាចទាញយកបានមកវិញ ឬផ្ទេរតាមប្រភេទណាមួយ ឬដោយមធ្យោបាយណាមួយ ជាអេឡិចត្រូនិច ជាម៉ាស៊ីន ជាការថតចំលង ជាការថតសម្លេង ឬដោយគ្មានការសុំអនុញ្ញាតជាលាយលក្ខណ៍អក្សរពីអ្នកបោះពុម្ពផ្សាយជាមុននោះទេ ។

# ផែនទីប្រទេសអាហ្វ្រិកខាងត្បូង និងប្រទេសកម្ពុជា



ប្រភពផែនទីនេះទទួលបានពី *Laura S. Johnson*

# ផែនទីផ្ទៃសមុទ្រជុំវិញប្រទេសអាហ្វ្រិកខាងត្បូង




ប្រភពរូបភាពផែនទីទទួលបានពី *Laura S. Johnson*

# អារម្ភកថា

របាយការណ៍នេះបានពិពណ៌នាអំពីបទពិសោធន៍នៃបុរសកម្ពុជាដែលត្រូវបានធ្លាក់ខ្លួនទៅក្នុងទាសភាពដោយការជួញដូរមនុស្ស ឬទទួលរងនូវការកេងប្រវ័ញ្ច ធ្ងន់ធ្ងរ នៅលើទូកនេសាទនៅក្នុងដែនទឹករបស់ប្រទេសអាហ្វ្រិកខាងត្បូង ។ លោកស្រី Rebecca Surtees អ្នកស្រាវជ្រាវជាន់ខ្ពស់បានប្រឡូកការងារសិក្សាស្រាវជ្រាវជាមួយ វិទ្យាស្ថាន NEXUS ផ្តោតការយកចិត្តទុកដាក់លើបញ្ហាជួញដូរមនុស្សនៅសមុទ្រមាន ជាអាទិ៍៖ លើផ្ទៃសមុទ្រ៖ ការជួញដូរមនុស្ស ក្នុងគោលបំណងកេងប្រវ័ញ្ចកម្លាំងពលកម្ម ក្នុងវិស័យនេសាទនៅសមុទ្រមកពីអ៊ុយក្រែន ។ ការប្រើប្រាស់ក្របខ័ណ្ឌច្បាប់ និង បទប្បញ្ញត្តិនានាក្នុងការបង្ការទប់ស្កាត់ និងប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្សយក ទៅនេសាទ និងការជួញដូរមនុស្សនៅសមុទ្រ។ ការកេងប្រវ័ញ្ចកម្លាំងពលកម្មផ្នែកនេសាទនៅអ៊ុយក្រែនជាដើម ។

ជាមួយគ្នានោះដែររបាយការណ៍ទាំងនេះចងក្រងរឿងរ៉ាវរបស់បុរសដែលស្វែងរកការងារដើម្បីជួយជីវភាពខ្លួន និងគ្រួសារតាមរយៈការងារយក្នុងឧស្សាហកម្មនេសាទ ឬ) ការងារផ្សេងៗទៀតនៅសមុទ្រ( ទោះបីជាការងារនេះប្រឈមខ្លាំងទៅនឹងទាសភាព អំពើហិង្សាខ្លាំង និងការកេងប្រវ័ញ្ចក្តី ។ បទពិសោធន៍ដ៏ជូរចត់របស់ពួកគេបង្ហាញពីសោកនាដកម្ម និងការរីករាលដាលនៃការជួញដូរនៅលើនាវាក្នុងផ្ទៃសាគរកើតមានឡើងនៅជុំវិញពិភពលោក ។

របកគំហើញក្នុងការសិក្សាស្រាវជ្រាវកន្លងមកជាទឡ្ហីករណ៍បន្ថែមលើរបាយ-ការណ៍ដែលលោកអ្នកកំពុងអាននេះកាន់តែច្បាស់ពីអំពើហឹង្សាលើរូបរាងកាយដើម្បីបង្ខំឲ្យធ្វើការងារនៅលើផ្ទៃសមុទ្រទ្វេឡើងថែមទៀត៖ *អ្នកឆ្លើយតបសំណួរ២នាក់ក្នុង*

> ចំណោមជនរងគ្រោះ៣១នាក់ដែលសម្ភាសក្នុងការសិក្សាស្រាវជ្រាវនេះទទួលការវាយដំលើរាងកាយនិងអំពើហឹង្សាខណៈពេលដែលកំពុងធ្វើការងារនៅលើនាវានេសាទក្នុងដែនសមុទ្រអាហ្វ្រិកខាងត្បូង...ពួកគេបានរៀបរាប់ការបំពានដ៏ធ្ងន់ធ្ងរលើពួកគេ ឧទាហរណ៍ - គេដាល់ វាយដំដោយដំបងឈើ ដំបងឫស្សី ឬប្រមាថដោយអាវុធជាដើម។
>
> បុរសម្នាក់ប្រាប់ថាគេវាយក្បាលគាត់ដោយថ្នោលទំពក់ដើម្បីបង្ខំឱ្យគាត់ទៅធ្វើការ។

ការលើកឡើងក្នុងការកិច្ចសម្ភាសន៍ក្នុងការសិក្ខាស្រាវជ្រាវនេះបានប្រៀបធៀបការធ្វើទុក្ខបុកម្នេញដែលពួកគេបានជួបប្រទះក្នុងខណៈខ្លួនជាជនរងគ្រោះនៃការជួញដូរ

មនុស្សនៅសមុទ្រថា៖ “សូម្បីតែនៅពេលដែលយើងមានការឈឺ ឬរងរបួសនោះពួកគេនៅតែបង្ខំយើងឱ្យធ្វើការ ...មើលទៅវាសាហាវជាងរបបប៉ុលពតទៅទៀត...”

ការដាក់ឲ្យស្ថិតនៅដាច់ឆ្ងាយនៃជនរងគ្រោះជាវិធីសាស្ត្រមួយដែលអ្នកជួញដូរមនុស្សប្រើប្រាស់ក្នុងគោលបំណងកាត់បន្ថយលទ្ធភាពរត់គេចខ្លួន ឬការជួយសង្គ្រោះពីអ្នកដទៃ ។ នាវានេសាទធំៗធ្វើអាជីវកម្មនេសាទនៅនាយសមុទ្ររយៈពេលយូរណាស់ដោយកម្រចូលមកកំពង់ផែ ដូច្នេះវាជាមជ្ឈដ្ឋានសមស្របបំផុតដល់អ្នកជួញដូរមនុស្សលាក់បាំងអំពើឧក្រិដ្ឋរបស់ខ្លួនដែលបានប្រព្រឹត្តទៅលើពលករ ដែលស្ថិតនៅលើនាវានោះ ។ នៅលើមហាសាគរដ៏ធំល្វឹងល្វើយ អ្នកជួញដូរមនុស្សបានប្រព្រឹត្តអំពើឃោរឃៅទៅលើរូបរាងកាយ និងស្មារតីរបស់ជនរងគ្រោះដែលកំពុងស្ថិតនៅឆ្ងាយពិបាករត់គេចដើម្បីស្វែងរកសេរីភាពខ្លួន ។

ថ្វីត្បិតតែការជួញដូរមនុស្សបានទទួលស្គាល់ថាជាអំពើឧក្រិដ្ឋយ៉ាងធ្ងន់ធ្ងរ និងជាការរំលោភលើសិទ្ធិមនុស្សជាសកលយ៉ាងណាក្តីជនប្រព្រឹត្តិល្មើសទាំងនោះរស់នៅយ៉ាងសុខសាន្តនៅលើផ្ទៃមហាសាគរល្វឹងល្វើយផុតពីសំណាញ់ច្បាប់ដដែល ។

របាយការណ៍នេះគូសបញ្ជាក់ពីបញ្ហាស្មុគ្រស្មាញទាំងឡាយដែលរដ្ឋាភិបាលនៅជុំវិញពិភពលោកប្រឈមមុខនឹងការមុនពេលពួកគេអាចមានលទ្ធភាពក្នុងការបញ្ចប់និទណ្ឌភាពរបស់ជនល្មើស និងផ្តល់កិច្ចគាំពារជនរងគ្រោះដោយសារការជួញដូរមនុស្សនៅលើផ្ទៃទឹកនៅលើផែនដីនេះ ។ ជំហានចាប់ផ្តើមមួយចំនួនដែលចាំបាច់សម្រាប់ការប្រយុទ្ធប្រឆាំងនឹងទម្រង់នៃការជួញដូរមនុស្សបែបនេះត្រូវបានរំលេចក្នុងការសិក្សាស្រាវជ្រាវបន្ទាប់ពីកិច្ចសម្ភាសន៍ជាមួយជនរងគ្រោះដោយផ្ទាល់ ។

នៅខណៈពេលដែលផ្នែកមួយនៃដំណោះស្រាយត្រូវតែជាការយកចិត្តទុក និងពង្រឹងការអនុវត្តលិខិតូបករណ៍ជាតិ និងអន្តរជាតិទៅនឹងការជួញដូរនៅលើផ្ទៃសមុទ្រច្បាប់ថ្មីៗប្រកបដោយសក្តានុពលសម្រាប់ប្រឆាំងនឹងទំរង់ជាក់លាក់នៃការជួញដូរត្រូវបានអនុម័តចូលជាធរមាន ។ អនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន និងពិធីសារ ទាក់ទិននឹងការប្រឆាំងការជួញដូរមនុស្ស (ពិធីសារប៉ាឡឺម៉ូ) អំពាវនាវដល់បណ្តាប្រទេសរបស់ទាំងអស់ធ្វើការរួមគ្នាដើម្បីលុបបំបាត់ការជួញដូរមនុស្សនៅជុំវិញពិភពលោក ។ វាមិនពាក់ព័ន្ធទៅនឹងអាណត្តិនៃការប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្សការកេងប្រវ័ញ្ចជាធាតុផ្សំនៃឧក្រិដ្ឋកម្មនៃការជួញដូរមនុស្សថាតើបានប្រព្រឹត្តនៅលើដី ឬនៅសមុទ្រនោះទេឬដូចនៅក្នុងករណីជាច្រើន) ការកេងប្រវ័ញ្ចកើតឡើងនៅរួមគ្នាទាំងនៅលើផ្ទៃសមុទ្រ

និងនៅលើដីគោក។ ទោះបីជាក្របខ័ណ្ឌច្បាប់ (អន្តរជាតិទាមទារឲ្យកាន់តែជាក់លាក់ និងរឹងមាំក្តី ការអនុវត្តដែលបានពិពណ៌នានៅក្នុងរបាយការណ៍ទាំងនេះ ជាកាតព្វកិច្ចសម្រាប់ប្រទេសក្នុងការកំណត់ដាក់ទណ្ឌកម្ម និងការប្រយុទ្ធជាការជួញដូរមនុស្ស ។

រដ្ឋាភិបាលនឹងត្រូវអនុម័តយុទ្ធសាស្ត្រដ៏ទូលំទូលាយតាមលក្ខណៈពិសេសមួយនៃទម្រង់ជួញដូរមនុស្សបែបនេះ ។ ពួកគេត្រូវតែជំរុញយុទ្ធសាស្ត្រថ្មីៗក្នុងការបង្កើត និងធានាឱ្យបាននូវប្រសិទ្ធិភាព តម្លាភាពក្នុងសង្វាក់ផ្គត់ផ្គង់ផលផលនេសាទ ។ នៅពេលអនាគតតាមរយៈការរួមបញ្ចូលគ្នានៃបច្ចេកវិទ្យាទូរគមនាគមន៍ការប្រាស្រ័យទាក់ទងគ្នាយ៉ាងឆាប់រហ័ស ការចែករំលែកព័ត៌មាន និងសារលើកកម្ពស់ការយល់ដឹងដែលផលិតដោយប្រព័ន្ធផ្សព្វផ្សាយសង្គម និងមធ្យោបាយផ្សេងទៀត អ្នកទទួលទាននឹងទទួលព័ត៌មានជាក់លាក់ដើម្បីសម្រេចចិត្តផលិតផលណាមួយដែលខ្លួននឹងប្រើប្រាស់ ។ អតិថិជននៃផលិតផលឧស្សាហកម្មនេសាទនឹងលើកទឹកចិត្តដល់ក្រុមហ៊ុនណាដែលលក់ផលផលនេសាទដោយមិនកេងប្រវ័ញ្ចកម្លាំងដូចដែលបានពិពណ៌នានៅក្នុងការស្រាវជ្រាវនេះ ។ អតិថិជននឹងធ្វើពហិការមិនប្រើប្រាស់ផលិតផលណាមួយ ពីក្រុមហ៊ុនដែលពាក់ព័ន្ធជាមួយរាល់ទម្រង់នៃការកេងប្រវ័ញ្ច ។

ខណៈពេលដែលការចូលរួមរបស់អតិថិជនកើនឡើង សហគមន៍អន្តរជាតិនឹងចាប់ផ្តើមកត់សម្គាល់ពីការចេញអាជ្ញាប័ណ្ណពីរដ្ឋាភិបាល ឬការអនុវត្តន៍របស់ក្រុមហ៊ុនដែលបានក្លាយជាគេស្គាល់ថាជាប់ទាក់ទិនទៅនឹង ឬជួយសម្រួលឲ្យមានការជួញដូរមនុស្ស ។

កាលណាមាននៃកិច្ចសហប្រតិបត្តិការអន្តរជាតិខ្លាំងក្លាតាមរយៈប្រទេសនានានៅលើពិភពលោកទទួលយក និងអនុវត្តតាមពិធីសារប៉ាឡឺម៉ូដើម្បីបង្កើតយុទ្ធសាស្ត្រ និងដំណោះស្រាយដែលមានចរិតជាអន្តរជាតិប្រកបដោយប្រសិទ្ធិភាពប្រឆាំងនឹងទម្រង់នៃការជួញដូរមនុស្សនេះ ។ វានឹងទាមទារឱ្យរដ្ឋាភិបាល សហគមន៍ពាណិជ្ជករ និង សង្គមស៊ីវិលធ្វើការរួមគ្នាដើម្បីទទួលបានជោគជ័យ ។

ការវិភាគ និងការរកឃើញមាននៅក្នុងរបាយការណ៍របស់វិទ្យាស្ថាន NEXUS ជាការអំពាវនាវឲ្យរដ្ឋាភិបាលទាំងឡាយចាត់វិធានការជាបន្ទាន់លើបញ្ហាជួញដូរមនុស្សសម្រាប់កេងប្រវ័ញ្ចពលកម្មលើទូកនេសាទនិងនៅតាម សមុទ្រនៅលើ) នាវាគ្រប់ប្រភេទ។ ( ដំណោះស្រាយទាំងអស់នឹងមិនមានភាពងាយស្រួលទេ ។ តែទោះជាយ៉ាងណាក្តីក៏ការជួញដូរមនុស្សនៅក្នុងវិស័យនេះអាចលុបបំបាត់បាន ។ ខ្ញុំសង្ឃឹមថាការស្រាវជ្រាវនេះនឹង

ដើរតួនាទីចែករំលែកព័ត៌មាន និងការជំរុញកិច្ចពិភាក្សាយ៉ាងម៉ត់ចត់នៅទូទាំងពិភពលោកស្តីពីការចាត់វិធានការដើម្បីបញ្ចប់ការធ្វើទាសភាពនៃមនុស្សនៅលើផ្ទៃសមុទ្រទាំងស្រុង ។


**លោក Stephen Warnath**

ស្ថាបនិក ប្រធាននិងជានាយកប្រតិបត្តិ

វិទ្យាស្ថាន **NEXUS**

**1701 Pennsylvania Ave NW**
**Washington, D.C. 20006**
**www.NEXUSInstitute.net**

# សេចក្តីថ្លែងអំណរគុណ

អត្ថបទសិក្សាស្រាវជ្រាវនេះ (និងទិដ្ឋភាពទូទៅនៃគម្រោង) ទទួលបានថវិកាឧបត្ថម្ភសប្បុរសធម៌ពីការិយាល័យពិនិត្យតាមដាននិងប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ក្រសួងការបរទេសសហរដ្ឋអាមេរិក (J/TIP) ។ គម្រោង សិក្សាស្រាវជ្រាវរួមគ្នារវាងអង្គការ IOM/វិទ្យាស្ថានNEXUS នេះបង្កើតឡើងដើម្បីពង្រឹងចំណេះដឹងថ្មីៗស្តីពីអំពើជួញដូរមនុស្សដោយបង្កើតការស្រាវជ្រាវកំណត់គោលដៅ ។ ការសិក្សាស្រាវជ្រាវនេះក៏មានគោលបំណងធ្វើការប៉ាន់ប្រមាណផងដែរអំពីវិធីសាស្រ្ត និងយុទ្ធសាស្រ្តនានាក្នុងការជួញដូរមនុស្សនាដំណាក់កាលផ្សេងៗគ្នា ហើយក៏ដើម្បីឆ្លើយតបទៅនឹងស្ថានភាពខុសៗគ្នាផងដែរ ។ សូមថ្លែងអំណរគុណការិយាល័យពិនិត្យតាមដាន និងប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស (J/TIP) របស់ក្រសួងការបរទេសសហរដ្ឋអាមេរិកសម្រាប់ការគាំទ្រដល់គម្រោង និងឆន្ទៈក្នុងការជួយជម្រុញការសិក្សាស្រាវជ្រាវនេះសម្រេចទៅបាន ។ យើងខ្ញុំក៏សូមថ្លែងអំណរគុណផងដែរដល់លោក Richard Danziger (អតីតប្រធានផ្នែកប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរបស់អង្គការ IOM នៅទីក្រុងហ្សឺណែវ បច្ចុប្បន្នជាប្រធានបេសកកម្មនៅប្រទេសអាហ្គានីស្ថាន) លោក Stephen Warnath (ស្ថាបនិក និងជាអគ្គនាយក និងប្រធានប្រតិបត្តិនៃវិទ្យាស្ថាន NEXUS នៅទីក្រុងវ៉ាស៊ីនតោន) និងអ្នកស្រី Sarah Craggs (អតីតអ្នកស្រាវជ្រាវរបស់អង្គការ IOM ស្នាក់ការកណ្តាល បច្ចុប្បន្នជាអ្នកឯកទេសផ្នែកជំនួយដល់ពលករទេសន្តរប្រវេសន៍ថ្នាក់តំបន់របស់អង្គការ IOM ថ្នាក់តំបន់នៅMENA Cairo) ដែលបានចូលរួមនៅក្នុងគម្រោង និងផ្តួចផ្តើមគំនិត ហើយនឹងថ្មីៗនេះគឺលោកLaurence Hart (ប្រធានផ្នែកជំនួយដល់ពលករទេសន្តរប្រវេសន៍របស់អង្គការ IOM ទីក្រុងហ្សឺណែវ) សម្រាប់ការគាំទ្រក្នុងដំណាក់កាលទី២នៃគម្រោងនេះ ។

អត្ថបទសិក្សាស្រាវជ្រាវនេះគឺផ្អែកលើការងារតាមមូលដ្ឋាននៅក្នុងប្រទេសកម្ពុជាឆ្នាំ ២០១៣-២០១៤ និងកិច្ចសម្ភាសន៍ជាមួយអ្នកជំនាញនៅប្រទេសអាហ្វ្រិកខាងត្បូងក្នុងឆ្នាំ ២០១៤ ។ ខ្ញុំសូមថ្លែងអំណរគុណកម្មករនេសាទកម្ពុជាដែលបានយល់ព្រមនិយាយអំពីរឿងរ៉ាវ បទពិសោធន៍ត្រូវបានគេជួញដូរ ព្រមទាំងបញ្ហាប្រឈមដែលពួកគេបានជួបប្រទះចាប់តាំងពីពេលដែលបានចាកចេញពីអំពើជួញដូរនោះមក ។ ទាំងនេះគឺជាកិច្ចសម្ភាសន៍ដ៏លំបាកមួយ ប៉ុន្តែពួកគាត់មានឆន្ទៈចង់ចែករំលែករឿងរ៉ាវឈឺចាប់របស់ពួកគាត់ ដើម្បីបង្កើតការសិក្សានេះឡើង។

ខ្ញុំក៏សូមថ្លែងអំណរគុណផងដែរដល់ អ្នកស្រី Helen Sworn (នាយិកាអន្តរជាតិ និងស្ថាបនិករបស់សម្ព័ន្ធចាប់ដៃកម្ពុជា) ដែលជាអ្នកលើកឡើងនូវបញ្ហារបស់បុរសកម្ពុ-ជាដែលត្រូវគេជួញដូរទៅកាន់ប្រទេសអាហ្វ្រិកខាងត្បូងសម្រាប់ការងារលើទូកនេសាទ ថាជាបញ្ហា

សំខាន់ក្នុងការសិក្សាស្រាវជ្រាវ ។ អ្នកស្រីក៏បានដើរតួជាជំនួយការដ៏អស្ចារ្យមួយរូបក្នុងការចែករំលែកព័ត៌មាន និងទំនាក់ទំនងបុគ្គលមួយចំនួននៅក្នុងប្រទេសកម្ពុជា និងអាហ្វ្រិកខាងត្បូង ហើយថែមទាំងជួយរៀបចំកិច្ចសម្ភាសន៍សាកល្បង នៅក្នុង កំឡុងពេលធ្វើការតាមមូលដ្ឋានផងដែរ ។ ខ្ញុំក៏សូមថ្លែងអំណរគុណផងដែរដល់បុគ្គលិកអង្គការមជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ (លោក ហ៊ុយ ពេជ្រសុវណ្ណ លោក Brandais York និងលោក Joel Preston) សមាគមន៍ការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា (អ្នកស្រី លឹម មុន្នី) សម្ព័ន្ធចាប់ដៃ (កញ្ញា ថូ ណារ៉ាន់ និងលោក យ៉ន ពេជ្រ) និងអង្គការជំនួយផ្នែកច្បាប់ដល់កុមារ និងស្ត្រី (អ្នកស្រី លី វិជ្ជុតា លោក ឈន រាសី និងលោក មុំ សុខចារ) សម្រាប់ការជួយទំនាក់ទំនង និងសម្របសម្រួលក្នុងដំណើរការសម្ភាសន៍ជាមួយកម្មករនេសាទកម្ពុជាសម្រាប់ការសិក្សាស្រាវជ្រាវនេះ។

អង្គការ IOM កម្ពុជាក៏ជាដៃគូយ៉ាងសំខាន់ផងដែរនៅក្នុងគម្រោងនេះ ខ្ញុំសូមថ្លែងអំណរគុណ លោក នុត សំអុល (បុគ្គលិកគម្រោង) ដែលបានធ្វើកិច្ចសម្ភាសន៍ជាមួយបុរសដែលត្រូវបានគេជួញដូរសម្រាប់ការងារនេសាទនៅអាហ្វ្រិកខាងត្បូង និងលោក Brett Dickson (មន្ត្រីគម្រោង) សម្រាប់ការជួយគាំទ្រនៅក្នុងគម្រោង និងជួយរៀបចំការងារស្រាវជ្រាវដល់មូលដ្ឋាន ។ ក៏សូមថ្លែងអំណរគុណ លោក នុត សំអុល និងលោក Brett Dickson ដែលបានជួយពិនិត្យមើល និងផ្តល់យោបល់ទៅលើការសិក្សា និងផ្តល់ជាអនុសាសន៍មួយចំនួនផងដែរ ។ កិច្ចគាំទ្រនេះត្រូវបានផ្តល់ផងដែរដោយអ្នកស្រី Zoe Rohde (ប្រធានអនុការិយាល័យរបស់អង្គការ IOM នៅទីក្រុង Cape Town) សម្រាប់ការជួយគាំទ្ររបស់គាត់ទៅលើការសិក្សាស្រាវជ្រាវ និងជួយធ្វើការទំនាក់ទំនងអ្នកផ្តល់ព័ត៌មានមួយចំនួននៅអាហ្វ្រិកខាងត្បូង ។ អ្នកស្រីក៏បានជួយពិនិត្យ និងផ្តល់យោបល់បន្ថែមទៅលើការសិក្សាស្រាវជ្រាវនេះផងដែរ។

ខ្ញុំក៏សូមថ្លែងអំណរគុណផងដែរទៅដល់អ្នកស្រី សេង សុភា (អ្នកបកប្រែឯករាជ្យ និងជំនួយការនៃការសិក្សាស្រាវជ្រាវ) ដែលបានផ្តល់ជំនួយយ៉ាងច្រើនអនេក ក្នុងការបកប្រែកំឡុងពេលសម្ភាសជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗ ព្រមទាំងបកប្រែ និងវាយអត្ថបទកិច្ចសម្ភាសន៍ជាមួយបុរសដែលត្រូវបានគេជួញដូរ ។ អ្នកស្រីក៏បានជួយក្នុងការរៀបចំកិច្ចសម្ភាសន៍កំឡុងពេលស្រាវជ្រាវដល់មូលដ្ឋានផងដែរ ។

ជាបន្តនេះ សេចក្តីថ្លែងអំណរគុណដ៏ស្មោះត្រង់ផងដែរដល់អ្នកជំនាញនៅក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងនៅក្នុងវិស័យនេសាទទាំងក្នុងប្រទេសកម្ពុជា និងអាហ្វ្រិកខាងត្បូង ដែលបានយល់ព្រមផ្តល់កិច្ចសម្ភាសន៍ និងចែករំលែកចំណេះដឹង និងជំនាញរបស់ពួកគាត់ ។ សូមថ្លែងអំណរគុណទៅដល់ស្ថាប័នជាតិ និងអង្គការមួយចំនួនដូចជា៖

**ប្រទេសកម្ពុជា:** ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ គណៈកម្មាធិការជាតិដឹកនាំបង្ក្រាបអំពើជួញដូរ រត់ពន្ធ កេងប្រវ័ញ្ចកម្លាំងពលកម្ម និងអាជីវកម្មលើស្ត្រី និងកុមារ ក្រសួងមហាផ្ទៃ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អង្គការជំនួយផ្នែកច្បាប់ដល់កុមារ និងស្ត្រី មជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ អង្គការអន្តរជាតិទេសន្តរប្រវេសន៍កម្ពុជា អង្គការពលកម្មអន្តរជាតិ សម្ព័ន្ធចាប់ដៃ អង្គការ Winrock អន្តរជាតិ អង្គការ UNIAP អង្គការជំហានដំបូង អង្គការ Love 146 សមាគម អ្នកការពារសិទ្ធិមនុស្ស និងការអភិវឌ្ឍន៍នៅប្រទេសកម្ពុជា និងអង្គការទស្សនៈពិភពលោក ។

**អាហ្វ្រិកខាងត្បូង:** អង្គការអន្តរជាតិទេសន្តរប្រវេសន៍នៅទីក្រុង Cape Town បណ្តាញសេរីភាពជាតិ (NFN) ក្រុមហ៊ុនមេធាវីផ្នែកនាវាចរ Alan Goldberg និងសហការីសហព័ន្ធកម្មករដឹកជញ្ជូនអន្តរជាតិ (ITF) សេវានគរបាលអាហ្វ្រិក (SAPS) សាវ៉ែកសមុទ្របេសកកម្មសម្រាប់កម្មករនាវា យុទ្ធនាការ A21 S-Cape នៅអាហ្វ្រិកខាងត្បូង មូលនិធិយុត្តិធម៌បរិស្ថាន(EJF) និងស្ថានទូតសហរដ្ឋអាមេរិក ។

អត្ថបទនេះក៏ទទួលបានផលប្រយោជន៍អំពីការផ្តល់យោបល់ និងរួមចំណែកពីអ្នកត្រួតពិនិត្យឯករាជ្យខាងក្រៅផងដែរ ។ សូមថ្លែងអំណរគុណ លោក Brandais York (ទីប្រឹក្សាត្រួតពិនិត្យ និងវាយតម្លៃ របស់អង្គការ CLEC កម្ពុជា) លោក លឹម ទិត្យ (អ្នកសម្របសម្រួលគម្រោងថ្នាក់ជាតិ របស់អង្គការ UNIAP កម្ពុជា) និងអ្នកស្រី Helen Sworn (នាយិកាអន្តរជាតិ និងស្ថាបនិករបស់សម្ព័ន្ធចាប់ដៃ) ។

ជាចុងក្រោយ ខ្ញុំសូមថ្លែងអំណរគុណទៅដល់បុគ្គលិកនៅក្នុងវិទ្យាស្ថាន NEXUS និងអង្គការ IOM ដែលបានធ្វើការដោយផ្ទាល់នៅក្នុងគម្រោងធ្វើការសិក្សាស្រាវជ្រាវរួមគ្នានេះ ។ នៅអង្គការ IOM សូមថ្លែងអំណរគុណទៅដល់អ្នកស្រី Ayima Okeeva (អ្នកស្រាវជ្រាវជាន់ខ្ពស់ និងអ្នកសម្របសម្រួលការវិភាគទិន្នន័យ) សម្រាប់ការគាំទ្រទូទៅរបស់អ្នកស្រីទៅក្នុងគម្រោង ព្រមទាំងផ្តល់យោបល់ និងសំណើរមួយចំនួននៅក្នុងអត្ថបទនេះ ។ សូមថ្លែងអំណរគុណផងដែរដល់បុគ្គលិកអង្គការ IOM ដែលបានពិនិត្យមើល និងផ្តល់យោបល់ត្រឡប់លើការសិក្សានេះដូចជា Ana Maria Martinez Castroagudin (មន្ត្រីកម្មវិធីអង្គការ IOM ទីក្រុងហ្សឺណែវ) Yoko Kimura (សហការីឯកទេសរបស់អង្គការ IOM ទីក្រុងហ្សឺណែវ) និង Rosilyne Borland (អ្នកឯកទេសបច្ចេកទេសថ្នាក់តំបន់ស្តីពីសិទ្ធិជនទេសន្តរប្រវេសន៍ និងក្រុមងាយរងគ្រោះនៅBuenos Aires ) ។

នៅវិទ្យាស្ថាន NEXUSខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅទៅដល់អ្នកស្រី Laura S. Johnson (សហការីស្រាវជ្រាវរបស់វិទ្យាស្ថានNEXUS) ដែលបានរួមចំណែកយ៉ាងច្រើនទៅក្នុងការសិក្សាស្រាវជ្រាវនេះ (និងគម្រោងទូទៅ) ។ អ្នកស្រីបានទទួលយកការងារជាច្រើនរួមទាំងបង្កើត និងវាយអត្ថបទកិច្ចសម្ភាសន៍ ជាមួយអ្នកផ្តល់ព័ត៌មានមួយចំនួននៅអា

ហ្វ៊ិកខាងត្បូង ផ្តល់ជាសារតាគ្រប់ទ្រង់ទ្រាយទាំងអស់នៃឧស្សាហកម្មនេសាទ ពិនិត្យ និងដាក់លេខកូដទិន្នន័យសម្ភាស រចនាផែនទី រករូបថតមួយចំនួន និងជួយកែសម្រួលរបាយការណ៍ ។ ប្រហែលជាផ្នែកសំខាន់បំផុតរបស់អ្នកស្រីនោះ គឺការពិនិត្យ និងផ្តល់យោបល់ទៅលើការសិក្សាស្រាវជ្រាវនេះ ។ ក៏សូមថ្លែងអំណរគុណផងដែរដល់ អ្នកស្រី Christina Parello (អ្នកវិភាគផ្នែកច្បាប់ និងអ្នកសម្របសម្រួលគម្រោងនៃវិទ្យាស្ថាន NEXUS) សម្រាប់ការពិនិត្យ យ៉ាង ប្រុងប្រយ័ត្ន និងផ្តល់យោបល់ទៅលើពង្រាងអត្ថបទស្រាវជ្រាវនេះ ។ ចុងក្រោយអរគុណយ៉ាងជ្រាលជ្រៅដល់លោក Stephen Warnath ដែលជាស្ថាបនិក និង អគ្គនាយកនៃវិទ្យាស្ថាន NEXUS បុគ្គលដែលខ្ញុំរីករាយនឹងធ្វើការជាមួយ ។ អត្ថបទនេះ និងការសិក្សាស្រាវជ្រាវនេះផងដែរបានទទួលផលប្រយោជន៍យ៉ាងច្រើនអំពីឯកទេស និងការផ្តល់យោបល់អំពីរូបលោក ។ ឆន្ទៈក្នុងការពង្រឹងការយល់ដឹងអំពីអំពើជួញដូរមនុស្សតាមរយៈការស្រាវជ្រាវបទពិសោធន៍គឺជាសរសរដ៏រឹងមាំរបស់គម្រោង ។

Rebecca Surtees
អ្នកស្រាវជ្រាវជាន់ខ្ពស់
វិទ្យាស្ថាន NEXUS
ទីក្រុងវ៉ាស៊ីនតោន ឌីស៊ី
www.nexusinstitute.net

# មាតិកា

បញ្ជីពាក្យកាត់និងអក្សរកាត់ .......................................................................... ១៤

សេចក្ដីសង្ខេប .......................................................................................... ១៦

១. សេចក្ដីផ្ដើម.......................................................................................... ១៦

២. វិធីសាស្ត្រស្រាវជ្រាវ និងការប្រមូលទិន្នន័យ .....................................................១៧

៣. និយមន័យនៃពាក្យ និងគោលគំនិត .................................................................. ២០

៤. តើនរណាជាជនរងគ្រោះ? កម្មករនេសាទកម្ពុជាត្រូវគេជួញដូរទៅ

និងមកពីប្រទេស អាហ្វ្រិកខាងត្បូង ........................................................ ២៤

៥. ការជ្រើសរើសកម្មករនេសាទកម្ពុជា- តួនាទីរបស់ទីភ្នាក់ងារ

ជ្រើសរើសពលករ Giant Ocean.............................................................២៥

៦. ពីប្រទេសកម្ពុជាទៅកាន់ប្រទេសអាហ្វ្រិកខាងត្បូង: វិធីដែលពលករ

ទាំងនោះធ្វើដំណើរ........................................................................... ២៧

៧. ការកេងប្រវ័ញ្ចនៅក្នុង និងក្រៅដែនទឹកអាហ្វ្រិកខាងត្បូង-

បទពិសោធន៍នៃការជួញដូរ.....................................................................២៨

៨. ការចាកចេញពីកប៉ាល់- ការចាកចេញ ការរត់គេចខ្លួន ការជួយសង្គ្រោះ

និងការដោះលែង.............................................................................. ៣២

៩. តាមផ្លូវត្រឡប់ទៅកាន់លំនៅដ្ឋានវិញ -ការវិលត្រឡប់ពីការជួញដូរមនុស្ស..........៣៣

១០. ជីវិតបន្ទាប់ពីការជួញដូរមនុស្ស- ការស្ដារ និងការធ្វើសមាហរណកម្ម

នៅក្នុងប្រទេសកម្ពុជា.......................................................................... ៣៥

១១. សេចក្ដីសន្និដ្ឋាន និងអនុសាសន៍ .................................................................. ៣៩

# បញ្ជីពាក្យកាត់ និងអក្សរកាត់

| | |
|---|---|
| ADHOC | សមាគមអ្នកការពារសិទ្ធិមនុស្ស និងការអភិវឌ្ឍន៍នៅប្រទេសកម្ពុជា |
| AT | ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស |
| CCA | តំបន់ត្រួតពិនិត្យពន្ធគយ |
| CLEC | មជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ |
| CT | អំពើជួញដូរមនុស្ស |
| DHA | ក្រសួងមហាផ្ទៃ |
| EEZ | តំបន់សេដ្ឋកិច្ចផ្តាច់មុខ |
| EJF | មូលនិធិយុត្តិធម៌បរិស្ថាន |
| FAO | អង្គការស្បៀងអាហារ និងកសិកម្មរបស់អង្គការសហប្រជាជាតិ |
| FCV | កប៉ាល់ជួលរបស់បរទេស |
| FoC | ទង់ជាតិដែលប្រើប្រាស់លើនាវាបរទេសដើម្បីភាពងាយស្រួលឆ្លងកាត់ |
| FoNC | ទង់ជាតិមិនអនុវត្តតាម |
| FSU | អតីតសហភាពសូវៀត |
| GO | អង្គការរដ្ឋាភិបាល |
| J/TIP | ការិយាល័យពិនិត្យតាមដាន និងប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ក្រសួងការបរទេសសហរដ្ឋអាមេរិក |
| HQ | ទីស្នាក់ការកណ្តាល |
| ILO | អង្គការពលកម្មអន្តរជាតិ |
| IMO | អង្គការសមុទ្រអន្តរជាតិ |
| IO | អង្គការអន្តរជាតិ |
| IOM | អង្គការអន្តរជាតិទេសន្តរប្រវេសន៍ |
| ITF | សហព័ន្ធពលករដឹកជញ្ជូនអន្តរជាតិ |
| IUU | ខុសច្បាប់ មិនរាយការណ៍ និងមិនប្រក្រតី |
| LICADHO | សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស |
| LSCW | ជំនួយផ្នែកច្បាប់ដល់កុមារ និងស្ត្រី |
| MLC | អនុសញ្ញាពលកម្មលើផ្ទៃសមុទ្រ |
| MoFAIC | ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ |
| MoI | ក្រសួងមហាផ្ទៃ |

| | |
|---|---|
| MoLVT | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| MoSAVY | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| MoU | អនុស្សរណៈនៃការយោគយល់គ្នា |
| NCCT | គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ពលកម្ម និងអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ |
| NFN | បណ្តាញសេរីភាពជាតិ |
| NGO | អង្គការមិនមែន/ក្រៅរដ្ឋាភិបាល |
| PSC | កំពង់ផែរដ្ឋ |
| RFO | អង្គការជលផលថ្នាក់តំបន់ |
| RFMO | អង្គការគ្រប់គ្រងវិស័យជលផលថ្នាក់តំបន់There |
| RSA | សាធារណរដ្ឋអាហ្វ្រិកខាងត្បូង |
| SEA | អាស៊ីអាគ្នេយ៍ |
| SEE | ប៉ែកអាគ្នេយ៍នៃទ្វីបអឺរ៉ុប |
| SIM | ម៉ូឌុល អត្តសញ្ញាណ អតិថិជន |
| TIP | អំពើជួញដូរមនុស្ស |
| UN | អង្គការសហប្រជាជាតិ |
| UNCLOS | អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ |
| UNIAP | គម្រោងអន្តរទីភ្នាក់ងារអង្គការសហប្រជាជាតិប្រឆាំងការជួញដូរមនុស្ស |
| UNODC | ការិយាល័យអង្គការសហប្រជាជាតិប្រឆាំងគ្រឿងញៀន និងឧក្រិដ្ឋកម្ម |
| US | សហរដ្ឋអាមេរិក |
| USD | ប្រាក់ដុល្លារអាមេរិក |
| VoT | ជនរងគ្រោះដោយអំពើជួញដូរមនុស្ស |
| WIF | អនុសញ្ញាស្តីពីការងារក្នុងវិស័យជលផល |

# សេចក្តីសង្ខេប

## ១. សេចក្តីផ្តើម

ការជួញដូរនៅក្នុងវិស័យឧស្សាហកម្មនេសាទនៅប្រទេសអាហ្វ្រិកខាងត្បូងត្រូវបានទទួលស្គាល់ និងយកចិត្តទុកដាក់កាន់តែខ្លាំងឡើងៗ នៅក្នុងចំណោមប្រព័ន្ធផ្សព្វផ្សាយ អ្នកស្រាវជ្រាវ អ្នកអនុវត្តកម្មវិធី និងអ្នកបង្កើតគោលនយោបាយនាប៉ុន្មានឆ្នាំថ្មីៗនេះ ។ ជនរងគ្រោះដោយអំពើជួញដូរមនុស្សនៅលើកប៉ាល់នេសាទជាទូទៅគឺជាបុរស (ហើយមួយចំនួនគឺជាក្មេងប្រុស) ដែលមកពីប្រទេសថៃ កម្ពុជា ភូមា ឥណ្ឌូនេស៊ី ដែលត្រូវបានគេកេងប្រវ័ញ្ចនៅក្នុងសមុទ្រថៃ ម៉ាឡេស៊ី និងឥណ្ឌូនេស៊ី ។ បុរសមួយចំនួនមកពីអាស៊ីអគ្នេយ៍ ត្រូវបានគេជួប្រទះនៅលើកប៉ាល់សែនឆ្ងាយពីផ្ទះ ដែលមកធ្វើការតាមរយៈទីភ្នាក់ងារជ្រើសរើសពលករស្របច្បាប់ ។ អត្ថបទសិក្សានេះរកឃើញ និងពិភាក្សាអំពីបទពិសោធន៍របស់បុរសកម្ពុជាដែលធ្វើទេសន្តរប្រវេសន៍ការងារនៅក្នុងឧស្សាហកម្មនេសាទ តាមរយៈទីភ្នាក់ងារជ្រើសរើសដែលបានទទួលអាជ្ញាប័ណ្ណស្របច្បាប់នៅប្រទសកម្ពុជាគឺទីភ្នាក់ងារជ្រើសរើសពលករ Giant Ocean International Fishery Company Limited (Giant Ocean) ដែលនៅទីបំផុតត្រូវបានគេជួញដូរ និងកេងប្រវ័ញ្ចនៅលើកប៉ាល់នេសាទឆ្ងាយពីច្រាំងអាហ្វ្រិកខាងត្បូង ។ ខណៈពេលដែលការប៉ាន់ប្រមាណចំនួនបុរសកម្ពុជាដែលត្រូវបានគេជួញដូរជាកម្មករនេសាទតាមរយៈទីភ្នាក់ងារជ្រើសរើស Giant Ocean មានភាពខុសៗគ្នា អ្វីដែលច្បាស់នោះគឺថាជនជាតិកម្ពុជារាប់រយនាក់ត្រូវបានគេកេងប្រវ័ញ្ចតាមវិធីនេះ ។ មន្ត្រីនគរបាលទទួលបានបណ្តឹងជាង ២០០ករណី ហើយប៉ាន់ស្មានថាបុរសប្រហែលជា ៧០០នាក់ ត្រូវបានបញ្ជូនទៅធ្វើការនៅលើទូកនេសាទក្រៅប្រទេសតាមរយៈទីភ្នាក់ងារជ្រើសរើសGiant Ocean នេះ ។ បុរសដែលត្រូវបានគេជួញដូរទាំងនោះក៏បានប្រាប់ផងដែរថា អ្នកភូមិ និងសហគមន៍ជាមួយគ្នាជាច្រើននាក់ ក៏បានទទួលយកការងារតាមរយៈទីភ្នាក់ងារជ្រើសរើស Giant Ocean នេះផងដែរ។

តួលេខខ្ពស់នៃកម្មករនេសាទដែលត្រូវគេជួញដូរតាមរយៈទីភ្នាក់ងារជ្រើសរើសពលករនៅក្នុងប្រទេសកម្ពុជាតែមួយប៉ុណ្ណោះ បានបង្កើនក្តីព្រួយបារម្ភយ៉ាងខ្លាំងក្នុងការរីករាលដាលនៃការជួញដូរ និងកេងប្រវ័ញ្ចនៃកម្មករនេសាទពីប្រទេសមួយ និងនៅក្នុងវិស័យនេសាទកាន់តែធំទៅៗ ។ វាក៏បានឆ្លុះបញ្ចាំងឲ្យឃើញផងដែរនូវកង្វះកិច្ចការពារនៅក្នុងប្រព័ន្ធជ្រើសរើស និងការរកការងារឲ្យធ្វើ ។ ការសិក្សាស្រាវជ្រាវនេះបានពិភាក្សាអំពីការជួញដូរបុរសកម្ពុជាសម្រាប់ការងារនេសាទនៅប្រទេសអាហ្វ្រិកខាងត្បូង និង/ឬ សមុទ្រអាហ្វ្រិកខាងត្បូង វិធីដែលបុរសទាំងនោះត្រូវបានជ្រើសរើស និងដឹកជញ្ជូន ព្រមទាំងបទពិសោធន៍នៅក្នុងសមុទ្រផងដែរ ។ ការសិក្សានេះក៏បានពិភាក្សាអំពីវិធីដែលកម្មករនេសាទ

ដែលត្រូវបានគេជួញដូរទាំងនោះ ត្រូវបាន (ហើយភាគច្រើនមិនត្រូវបាន) គេកំណត់ អត្តសញ្ញាណថាជាជនរងគ្រោះដោយសារអំពើជួញដូរនៅក្នុងអាហ្វ្រិកខាងត្បូងឡើយ ហើយថាតើជំនួយអ្វីដែលពួកគាត់បាន (ឬមិនបាន)ទទួល នៅពេលដែលពួកគាត់រត់គេច និងត្រឡប់ទៅផ្ទះវិញនៅប្រទេសកម្ពុជា ព្រមទាំងបានស្វែងរកការជួយធ្វើសមាហរណកម្មត្រឡប់ទៅកាន់គ្រួសារ និងសហគមន៍របស់ពួកគាត់វិញ ។

ការសិក្សាស្រាវជ្រាវនេះមានបំណងផ្តល់សំឡេងដល់បុរសកម្ពុជាដែលត្រូវបានគេជួញដូរលើកប៉ាល់នេសាទ ហើយនឹងបង្កើនការយល់ដឹងអំពីរឿងរ៉ាវដែលបានកើតឡើងចំពោះពួកគាត់នៅពេលដែលពួកគាត់បានធ្វើទេសន្តរប្រវេសន៍ការងារ ដោយស្របច្បាប់ទៅក្រៅប្រទេស ។ មានទ្រង់ទ្រាយនៃបទពិសោធន៍របស់ពួកគាត់ រួមទាំងបរិបទជ្រើសរើសផ្លូវការស្របច្បាប់ដែលពួកគាត់បានឆ្លងកាត់ ហើយអាចបង្ហាញឲ្យឃើញនូវភាពងាយរងគ្រោះប្លែកៗ ជាពិសេសគឺកង្វះកិច្ចការពារពីក្រុមហ៊ុនជ្រើសរើស និងដាក់ឲ្យធ្វើការងារ មិនបានផ្តល់នៅក្នុងប្រព័ន្ធរបស់ខ្លួន ។ ការសិក្សានេះផ្តោតទៅលើអ្វីដែលយើងអាចរៀនសូត្របានពីបទពិសោធន៍ទាំងនោះ ដើម្បីជាព័ត៌មានសម្រាប់អ្នកបង្កើតគោលនយោបាយ និងកម្មវិធីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងដើម្បីពង្រឹងការឆ្លើយតប និងកិច្ចអន្តរាគមន៍សម្រាប់កម្មករនេសាទដែលត្រូវបានគេជួញដូរទៅសមុទ្រនោះបានកាន់តែប្រសើរឡើង។

# វិធីសាស្ត្រស្រាវជ្រាវ និងការប្រមូលទិន្នន័យ

## ២.១. វិធីសាស្ត្រស្រាវជ្រាវ

អត្ថបទសិក្សាស្រាវជ្រាវនេះពឹងផ្អែកទៅលើបទពិសោធន៍របស់បុរសជនជាតិកម្ពុជាចំនួន ៣១ នាក់ដែលត្រូវបានគេជួញដូរទៅលើទូកនេសាទនៅអាហ្វ្រិកខាងត្បូងរវាងឆ្នាំ ២០១០ និង ២០១៣ ។ បុរសចំនួន ១១ នាក់បានសម្ភាសន៍នៅក្នុងខែ មករា ឆ្នាំ២០១៤។ កិច្ចសម្ភាសន៍ផ្តោតទៅលើបទពិសោធន៍ត្រូវបានគេជួញដូរ (ជ្រើសរើស ដឹកជញ្ជូន កេងប្រវ័ញ្ច ចាកចេញពីការជួញដូរ និងទទួលបានការជួយគាំទ្រណាមួយ) ស្ថានភាពបច្ចុប្បន្នរបស់ពួកគាត់ និងផែនការអនាគត និងតម្រូវការរបស់ពួកគាត់ ។ សំណុំរឿងចំនួន ២០ បន្ថែមទៀតរបស់បុរសកម្ពុជាដែលត្រូវបានគេជួញដូរទៅលើទូកនេសាទនៅអាហ្វ្រិកខាងត្បូងត្រូវបានសម្ភាសន៍ ដាក់លេខកូដ និងវិភាគដោយប្រើប្រាស់ក្របខ័ណ្ឌ និងការចាត់ប្រភេទវិភាគដូចគ្នា ។ លើសពីនេះទៀត កិច្ចសម្ភាសន៍ត្រូវបានរៀបចំឡើងជាមួយបុរសកម្ពុជាចំនួន ៧ នាក់ផ្សេងទៀតដែលត្រូវបានជ្រើសរើសតាមរយៈទីភ្នាក់ងារជ្រើសរើស Giant Ocean ប៉ុន្តែត្រូវបានរកឃើញមានការកេងប្រវ័ញ្ចនៅលើកប៉ាល់នេសាទនៅប្រទេសហ្វីជី និងម័រីទុស ។

កិច្ចសម្ភាសន៍ត្រូវបានរៀបចំឡើងជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗចំនួន ៤២ នាក់ ក្នុងកំឡុងពេលធ្វើការស្រាវជ្រាវនេះ ទាំងនៅក្នុងប្រទេសកម្ពុជា និងអាហ្វ្រិកខាងត្បូង ។ ការស្រាវជ្រាវដល់ទីកន្លែងចំនួន ៤ លើកបានរៀបចំឡើងនៅប្រទេសកម្ពុជានា ខែសីហា ឆ្នាំ២០១៣ ដល់ខែមករា ឆ្នាំ២០១៤ និង២លើកទៀតនៅខែមីនា ឆ្នាំ២០១៤ ។ ជាសរុប អ្នកផ្តល់ព័ត៌មានសំខាន់ៗចំនួន ២៨នាក់ត្រូវបានសម្ភាសន៍ ដែលពួកគាត់តំណាងឲ្យអង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងមន្ត្រីក្រសួងសំខាន់ៗរបស់រាជរដ្ឋាភិបាលកម្ពុជា ។ ដោយឡែកមានករណីចំនួន ៦ ដែលអ្នកផ្តល់ព័ត៌មានសំខាន់ៗ ត្រូវបានសម្ភាសន៍លើសពីម្តង។

កិច្ចសម្ភាសន៍ត្រូវបានរៀបចំឡើងជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗចំនួន ១៤ នាក់ នៅក្នុងប្រទេសអាហ្វ្រិកខាងត្បូង នាខែធ្នូ ឆ្នាំ២០១៣ ដល់ខែឧសភា ឆ្នាំ២០១៤ ដែលពួកគាត់តំណាងឲ្យអង្គការមិនមែនរដ្ឋាភិបាល និងសង្គមស៊ីវិល អង្គការអន្តរជាតិ រដ្ឋាភិបាល អ្នកស្រាវជ្រាវ និងស្ថានទូត រួមទាំងអ្នកឯកទេសខាងនេសាទខុសច្បាប់ IUU ដើម្បីរៀនអំពីបញ្ហានៅក្នុងឧស្សាហកម្មទូទៅ ក៏ដូចជានៅក្នុងបរិបទនៃឧស្សាហកម្មនេសាទខុសច្បាប់ IUU នៅក្នុង និងជុំវិញអាហ្វ្រិកខាងត្បូងផងដែរ ។

## ២.២. ភាពនៅមានកម្រិតនៃវិធីសាស្ត្រ

ការសិក្សានេះផ្តោតសំខាន់តែទៅលើជនជាតិកម្ពុជាដែលត្រូវគេជួញដូរតាមរយៈទីភ្នាក់ងារជ្រើសរើស Giant Ocean តែប៉ុណ្ណោះ ។ ដូចជាការជ្រើសរើសតាមរយៈភ្នាក់ងារផ្លូវការ «ស្របច្បាប់» ធ្វើទេសន្តរប្រវេសន៍ដោយមានឯកសារស្របច្បាប់ និងលិខិតអនុញ្ញាតការងារ ។ល។ ការសិក្សានេះតំណាងឲ្យបទពិសោធន៍ និងគន្លងនៃការជួញដូរដ៏ជាក់លាក់មួយ និងមិនតំណាងឲ្យបទពិសោធន៍ និងតម្រូវការនៃកម្មករនេសាទដែលត្រូវបានគេជួញដូរទូទៅនោះទេ ។ ជាអាទិ៍បុរសកម្ពុជាជាច្រើនត្រូវបានគេជួញដូរតាមរយៈប្រព័ន្ធមិនស្របច្បាប់ និងទៅតាមសណ្ឋានជ្រើសរើសខុសៗគ្នា ។ បទពិសោធន៍ និងតម្រូវការរបស់ពួកគេទំនងជាមានភាពខុសៗគ្នាទៅតាមផ្នែក និងកម្រិតនៃការកេងប្រវ័ញ្ចនិមួយៗ ដែលបុរសត្រូវគេជួញដូរទៅលើទូកនេសាទបានជួបប្រទះនៅអាហ្វ្រិកខាងត្បូង ។ ការកំណត់នូវកិច្ចអន្តរាគមន៍ដ៏សមរម្យនៅក្នុងករណីទាំងនេះ នឹងទាមទារការស្រាវជ្រាវធ្វើការវាស់វែងទៅតាមបទពិសោធន៍ និងតម្រូវការជាក់លាក់របស់ពួកគេ ។

គំរូនៃការសិក្សានេះអាចមានទំហំតូច បើប្រៀបធៀបទៅនឹងចំនួនបុរសដែលត្រូវបានគេជ្រើសរើស និងប្រហែលជាអាចជួញដូរតាមរយៈទីភ្នាក់ងារជ្រើសរើសGiant Ocean រាប់រយនាក់ ។ ការកំណត់រក និងទំនាក់ទំនងទៅអ្នកផ្តល់ព័ត៌មានមានបញ្ហាលំបាកដោយសារពេលវេលាខ្លីសម្រាប់ការប្រមូលទិន្នន័យ និងពាក់ព័ន្ធដល់ការធ្វើដំណើរ ។ ដូចនេះការ

សិក្សានេះមិនអាចតំណាងឲ្យបទពិសោធន៍ជួញដូរ និងតម្រូវការជួយគាំទ្រទូលំទូលាយបានទេ ។

ទិន្នន័យនៃការសម្ភាសន៍នេះក៏មានភាពលម្អៀងផងដែរ ។ វាជាការលំបាកសម្រាប់បុរសទាំងនោះក្នុងការផ្តល់ព័ត៌មានទៅលើប្រធានបទមួយចំនួន ។ ព័ត៌មានខ្លះពួកគាត់មិនបានចងចាំទេ ហើយមួយចំនួនទៀតពួកគាត់អាចនឹងរើសយកការមិនចងចាំ ដើម្បីចៀសវាងការគិត និងពិភាក្សាអំពីកាលៈទេសៈលំបាកបំផុតនៅក្នុងឆាកជីវិតរបស់ពួកគាត់ ។ ពេលខ្លះបុរសទាំងនោះមិនយកចិត្តទុកដាក់ចំពោះប្រភេទព័ត៌មានជាក់លាក់ទេ ឧ. ព័ត៌មានលំអិតអំពីកប៉ាល់ សមាជិកនៅក្នុងកប៉ាល់ និងព័ត៌មានផ្សេងៗទៀត ។ នៅក្នុងករណីខ្លះទៀត ព័ត៌មានខ្លះបុរសទាំងនោះមិនបានដឹងតែម្តងដោយសារភាពខុសគ្នានៃភាសានៅលើទូក ក៏ដូចជានៅក្នុងប្រទេសអាហ្វ្រិកខាងត្បូង (បុរសទាំងនោះជារឿយៗមិនអាចទំនាក់ទំនងជាមួយ ឬយល់អំពីសមត្ថកិច្ច និងអ្វីដែលកើតឡើងនៅអាហ្វ្រិកខាងត្បូងឡើយ) ។ វាមានការលំបាកក្នុងការទំនាក់ទំនងជាមួយអ្នកផ្តល់ព័ត៌មានផងដែរ ជាពិសេសនៅអាហ្វ្រិកខាងត្បូង ដែលមិនអាចឲ្យយើងធ្វើការស្រាវជ្រាវដល់ទីកន្លែង ហើយអាចត្រឹមតែរៀបចំកិច្ចសម្ភាសន៍ជាមួយមន្ត្រីពីខាងរដ្ឋាភិបាលតែម្នាក់ប៉ុណ្ណោះ ។ នេះមានន័យថាមានព័ត៌មានពីប្រទេសគោលដៅ អាចជាប្រយោជន៍សម្រាប់ការយល់ដឹងកាន់តែប្រសើរឡើងអំពីអ្វីដែលកើតឡើងនៅក្នុងករណីទាំងនោះ។

## ២.៣.បញ្ហាក្រមសីលធម៌

កិច្ចសម្ភាសន៍និមួយៗបានចាប់ផ្តើមដោយមានការជូនដំណឹងលម្អិតអំពីដំណើរការនៃការទទួលការយល់ព្រមជាមុន ដែលរួមមានការពន្យល់អំពីគោលបំណងនៃការសិក្សា សំណួរដែលនឹងត្រូវចោទសួរ សិទ្ធិរបស់ពួកគេក្នុងការបដិសេធសំណួរណាមួយ ឬបញ្ចប់ការសម្ភាសន៍នៅពេលណាមួយ និងធានារក្សាការសំងាត់ ។ កិច្ចសម្ភាសន៍ត្រូវបានរៀបចំឡើងនៅទីតាំងដែលជ្រើសរើសឡើងដោយអ្នកឆ្លើយតប ។ រាល់កិច្ចសម្ភាសន៍ទាំងអស់គឺបានរក្សាការសំងាត់យ៉ាងតឹងតែង និងធានាសុវត្ថិភាពដោយយោងតាមគោលនយោបាយរក្សាទិន្នន័យផ្ទៃក្នុងរបស់វិទ្យាស្ថាន NEXUS ។ អ្នកស្រាវជ្រាវត្រូវបានផ្តល់ឲ្យនូវព័ត៌មានអំពីសេវាបញ្ជូនបន្តក្នុងពេលបច្ចុប្បន្នស្តីពីសេវាកម្ម និងភ្នាក់ងារដែលផ្តល់ការគាំទ្រ និងជំនួយតាមប្រភេទផ្សេងៗ ។ អ្នកឆ្លើយតបទាំងអស់ទទួលបានឯកសារសេវាបញ្ជូនបន្តនេះ ដែលជាផ្នែកមួយនៃដំណើរការកិច្ចសម្ភាសន៍ ។ ដោយសារបញ្ហាសគុណអាចនឹងបង្កើតនូវសម្ពាធក្នុងការចូលរួមក្នុងដំណើរការស្រាវជ្រាវ ជាវិធីដើម្បីទទួលបានការយល់ព្រម ដូចនេះសគុណមិនត្រូវបានផ្តល់ជូន ក្នុងផ្នែកណាមួយនៃការសិក្សានេះទេ ។ ប៉ុន្តែមូលនិធិមួយចំនួនត្រូវបានផ្តល់ជូនដល់អ្នកឆ្លើយតប ដើម្បីរ៉ាប់រងការស្នាក់នៅ ការហូកចុក និងធ្វើដំណើរនៅពេលដែលកិច្ចសម្ភាសន៍ត្រូវបានធ្វើឡើងក្រៅពីផ្ទះរបស់ពួកគេ ។ «អំណោយ» តិចតួច (ឧ. អាហារបរិភោគ) ជាសំណងសម្រាប់ការបាត់បង់ប្រាក់ចំណូល ។

# ៣. និយមន័យ ពាក្យ និងគោលគំនិត

និយមន័យ ពាក្យ និងទស្សនទានដែលប្រើនៅក្នុងការសិក្សានេះគឺនៅជុំវិញប្រធានបទពីរសំខាន់ ១/ ផ្អែកទាំងមូលផ្តោតលើការយល់ដឹងអំពីការជួញដូរមនុស្ស និងជាពិសេសផ្តោតទៅលើការជួញដូរនៅលើផ្ទៃសមុទ្រ និង ២/ ផ្តោតទៅលើឧស្សាហកម្ម នេសាទ ។

## ៣.១. ការយល់ដឹងអំពីអំពើជួញដូរមនុស្ស

**ការជួញដូរមនុស្ស:** អំពើជួញដូរនៅក្នុងការសិក្សានេះសំដៅទៅលើនិយមន័យដែលមានចែងនៅក្នុងពិធីសារអង្គការសហប្រជាជាតិដើម្បីបង្ការទប់ស្កាត់ ផ្តន្ទាទោស និងដាក់ទណ្ឌកម្មអំពើជួញដូរមនុស្ស ដែលបានឲ្យនិយមន័យអំពើជួញដូរមនុស្សថា:

> (...) ការជ្រើសរើស ដឹកជញ្ជូន ផ្ទេរ សំចត ឬទទួលមនុស្ស ដោយមធ្យោបាយគម្រាមកំហែង ឬប្រើប្រាស់កម្លាំង ឬទម្រង់ផ្សេងទៀតនៃការបង្ខំ អំពើពង្រត់ បោកបញ្ឆោត បន្លំ បំពានដោយអំណាច ឬបំពានភាពងាយរងគ្រោះ ឬដោយផ្តល់ ឬទទួលប្រាក់កម្រៃ ឬផលប្រយោជន៍ ដើម្បីទទួលបានការយល់ព្រមពីបុគ្គលក្នុងការត្រួតត្រាលើអ្នកណាម្នាក់ សម្រាប់គោលបំណងកេងប្រវ័ញ្ច។ កេងប្រវ័ញ្ចជាអប្បបរមាអាចរួមមាន: ការកេងប្រវ័ញ្ចអំពើពេស្យាចាររបស់ជនដទៃ ឬទម្រង់ផ្សេងទៀតនៃការកេងប្រវ័ញ្ចផ្លូវភេទ ពលកម្ម ឬសេវាកម្មដោយបង្ខំ ទាសភាព ឬការអនុវត្តស្រដៀងគ្នាទៅនឹងទាសភាព សេវភាព ឬការដកហូតអវៈយវៈ ។

**ការជួញដូរនៅសមុទ្រ:** គឺជាការជួញដូរដែលកើតឡើងនៅទីកន្លែងមួយដែលពាក់ព័ន្ធនឹងកម្មករនាវា និងកម្មករនេសាទនៅក្នុងបរិបទសកម្មភាពទាំងឡាយណានៅសមុទ្រ។

- *កម្មករនេសាទ:* គឺជាបុគ្គលដែលត្រូវបានគេជួល ឬជាប់កិច្ចសន្យានៅក្នុងសមត្ថកិច្ចណាមួយ ឬចាប់យកអាជីពណាមួយនៅលើកប៉ាល់នេសាទ ដោយរាប់ទាំងបុគ្គលដែលធ្វើការនៅក្នុងកប៉ាល់ដែលទទួលប្រាក់ឈ្នួលតាមការចែកភាគផលដែលចាប់បាន ប៉ុន្តែមិនរាប់បញ្ចូលអ្នកបើកបរ បុគ្គលិកនាវា បុគ្គលផ្សេងទៀតនៅក្នុងសេវាអចិន្ត្រៃយ៍របស់រដ្ឋាភិបាល បុគ្គលិកតាមច្រាំងសមុទ្រដែលធ្វើក្រៅកប៉ាល់នេសាទ និងអ្នកឃ្លាំមើលផលិតផលជលផលនោះទេ ។
- *កម្មករនាវា:* គឺជាបុគ្គលណាដែលត្រូវបានជួល ឬជាប់កិច្ចសន្យានៅក្នុងសមត្ថកិច្ចណាមួយនៅក្នុងនាវា ទោះបីជាសាធារណៈ ឬឯកជនក្តី ជាទូទៅចូលរួមក្នុងសកម្មភាពនាវាពាណិជ្ជកម្ម ជាជាងពាក់ព័ន្ធនឹងនាវានេសាទ ។

**«វិធីសាស្រ្ត P ទាំងបី»**នៃការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរួមមាន៖ ការបង្ការទប់ស្កាត់ កិច្ចការពារ និងការផ្តន្ទាទោស។

- *ការបង្ការទប់ស្កាត់* សំដៅទៅលើការបង្ការសកម្មភាពជួញដូរ ។ នៅក្នុងបរិបទទប់ស្កាត់ការជួញដូរកម្មករនេសាទ អាចផ្តោតទៅលើការបង្កើនការយល់ដឹងអំពីគ្រោះថ្នាក់នៃអំពើជួញដូរនៅក្នុងវិស័យការងារ ទាំងតាមរយៈប្រព័ន្ធស្របច្បាប់ និងមិនស្របច្បាប់។
- *កិច្ចការពារ* សំដៅទៅលើកិច្ចការពារជនត្រូវបានគេជួញដូរ ដែលទាមទារទាំងការកំណត់ជាផ្លូវការអំពីអត្តសញ្ញាណជនរងគ្រោះដោយសារអំពើជួញដូរ និងការផ្តល់ជំនួយ (ដោយស្ម័គ្រចិត្ត) គោលបំណងដើម្បីស្តារ និងសមាហរណកម្មជនដែលត្រូវបានគេជួញដូរនោះ។
- *ការផ្តន្ទាទោស* ការផ្តន្ទាទោសសំដៅទៅលើសកម្មភាពយុត្តិធម៌ព្រហ្មទណ្ឌជាច្រើនដំណាក់កាល ដោយចាប់ផ្តើមពីការស៊ើបអង្កេតសកម្មជាមុន និងបញ្ចប់ដោយការផ្តន្ទាទោសដល់ជនប្រព្រឹត្តបទឧក្រិដ្ឋជួញដូរមនុស្ស និងបញ្ចប់អាជីវកម្មដែលប្រព្រឹត្តបទឧក្រិដ្ឋ ប៉ុន្តែក៏អាចរាប់បញ្ចូលទាំងបណ្តឹងរដ្ឋប្បវេណី ឬបណ្តឹងផ្សេងទៀត (ឧ. បណ្តឹងរដ្ឋបាល)។

## ៣.២. ទ្រង់ទ្រាយនៃឧស្សាហកម្មនេសាទ និងការងារនៅសមុទ្រ

*ការនេសាទខុសច្បាប់ IUU* ៖ ការនេសាទខុសច្បាប់ មិនបានរាយការណ៍ និងមិនមានភាពប្រក្រតី គឺជាការនេសាទដែលកើតឡើងដោយគ្មាន ឬដោយរំលោភអាជ្ញាប័ណ្ណនេសាទ ក្នុងតំបន់ការពារ ឬដោយគ្មានការរាយការណ៍ពីផលិតផលដែលចាប់បានក្នុងសមុទ្រ ដោយយោងទៅតាមបទបញ្ជានេសាទ ។

*កប៉ាល់នេសាទ៖* គឺជាកប៉ាល់ដែលប្រើប្រាស់សម្រាប់អាជីវកម្មនេសាទត្រី សត្វសមុទ្រ ឬជីវធនធាននៅក្នុងសមុទ្រ ។

- *កប៉ាល់អូសមង៖* ជាកប៉ាល់នេសាទណាដែលស្ថិតនៅលើផ្ទៃសមុទ្ររយៈពេលយូរខែ រហូតដល់ឆ្នាំក៏មាន មុនពេលចូលចតនៅកំពង់ផែ ។ (ការនេសាទអូសមងនេះជាប្រភេទនេសាទជាក់លាក់មួយដែលប្រមូលផលដែលគេកំណត់តែប៉ុណ្ណោះ ។ គេ

ប្រើកប៉ាល់ពីមកអូសមង ចម្ងាយដ៏ឆ្ងាយហើយចាប់ផ្តើមព័ទ្ធជារង្វង់ ហើយទូកតូចៗ បើកចូលក្នុងរង្វង់នៅដើម្បីចាប់ត្រីតែម្តង) ។

- *កប៉ាល់អូសមងបណ្តែត និងកប៉ាល់វាយមងបណ្តែត៖* ការវាយមងបណ្តែត គឺជាវិធីសាស្រ្តដាក់មងព្យួរចុះក្រោមត្រង់ ហើយអូសឆ្ងាយពីកប៉ាល់។ កប៉ាល់ដែលប្រើវិធីសាស្រ្តវាយមងបណ្តែតនេះហៅថា កប៉ាល់វាយមងបណ្តែត។
- *ការនេសាទដោយប្រើសន្ទូចរនង ឬសន្ទូចសាង និងកប៉ាល់ប្រើសន្ទូចរនង ឬសន្ទូចសាង:*គឺជាប្រភេទនៃការប្រមូលផលនេសាទមួយដោយប្រើសន្ទូច («សន្ទូចរនង ឬសន្ទូចសាង») គឺត្រូវអូសយ៉ាងឆ្ងាយពីកប៉ាល់។ ខ្សែសន្ទូចនេះគឺត្រូវបានរក្សាទុកឲ្យអណ្តែតដោយពោង ហើយនៅចន្លោះខ្សែសន្ទូចនីមួយៗ មានខ្សែសន្ទូចទីពីរភ្ជាប់បន្លាយចុះក្រោមទៅក្នុងទឹក។ កប៉ាល់ដែលប្រើប្រាស់សន្ទូចរនង ឬសន្ទូចសាងនេះហៅថាកប៉ាល់ប្រើសន្ទូចរនង ឬសន្ទូចសាង។
- *កប៉ាល់ក្លាសេ៖* ជាកប៉ាល់បំពាក់ដោយឧបករណ៍សម្រាប់ក្លាសេ វាដើរតួជាកប៉ាល់មេ ប្រមូលយកផលិតផលនេសាទពីកប៉ាល់ផ្សេងៗទៀតនៅលើផ្ទៃសមុទ្រ ។
- *ការផ្ទេរចេញពីកប៉ាល់៖* គឺជាការផ្ទេរទំនិញ ឬត្រីចេញពីកប៉ាល់មួយទៅកាន់កប៉ាល់មួយទៀត ។

*ការអនុវត្តការជ្រើសរើសពលករសម្រាប់ការងារនេសាទ*

- *មេខ្យល់៖* គឺជាបុគ្គលដែលជ្រើសរើសបុគ្គលណាម្នាក់ ទៅធ្វើការជាកម្មករនៅលើកប៉ាល់នេសាទ ។
- *ទីភ្នាក់ងារកម្មករនេសាទ៖* គឺជាក្រុមហ៊ុនឯកទេសមួយដែលធ្វើការជ្រើសរើសកម្មករនេសាទ និងនាវិកទៅឲ្យកប៉ាល់ដែលត្រូវការកម្មករ ក៏អាចហៅថាទីភ្នាក់ងារជ្រើសរើសផងដែរ។
- *ក្រុមហ៊ុននេសាទ៖* គឺជាក្រុមហ៊ុនដែលពឹងផ្អែកទៅលើទំហំ និងព្រំដែន កែច្នៃផលិតផលពីសមុទ្រ និង/ឬជាទីផ្សារត្រី ។

*ច្បាប់នេសាទ*

- *លំហរសមុទ្រ៖* ជាផ្នែកទាំងឡាយនៃសមុទ្រ ដែលមិនស្ថិតនៅក្រោមអធិបតេយ្យភាព ឬយុត្តាធិការនៃរដ្ឋណាមួយ។

- *ការគ្រប់គ្រង ផ្តល់ទង់ជាតិដោយរដ្ឋ៖* គឺជាប្រព័ន្ធនៃយុត្តាធិការនៅលំហរសមុទ្រ ដែលកប៉ាល់ទាំងអស់ត្រូវតែចុះបញ្ជីនៅប្រទេសណាមួយ និងដាក់ទង់ជាតិប្រទេសនោះ ។
- *ទង់ជាតិដែលប្រើប្រាស់លើនាវាបរទេសដើម្បីភាពងាយស្រួលឆ្លងកាត់៖* គឺជាទង់ជាតិរបស់រដ្ឋមួយ បើកចំហរក្នុងការបញ្ជី ដែលមិនអាច ឬមិនមានចេតនាបង្ហាញអត្តសញ្ញាណទង់ជាតិរបស់រដ្ឋខ្លួន (ទាំងក្នុងន័យប្រតិបត្តិច្បាប់ជាតិដែលមានស្រាប់ ឬទាំងក្នុងន័យអនុវត្តច្បាប់)
- *ទង់ជាតិមិនប្រតិបត្តិតាម៖* គឺជាទង់ជាតិរដ្ឋដែលមិនចាំបាច់ចុះបញ្ជីការ ដូចជាទង់លើនាវាបរទេសបានទេ ប៉ុន្តែមិនអនុវត្តកាតព្វកិច្ចរបស់រដ្ឋផ្តល់ទង់ជាតិ ជាពិសេសនៅក្នុងលំហរសមុទ្រ ឬចម្ងាយផ្ទៃទឹកនេសាទ។
- *បូរណភាពដែនសមុទ្រ៖* បូរណភាពដែនសមុទ្រ (ឬព្រំដែនសមុទ្រ) គឺជាផ្ទៃសមុទ្រដែលជាផ្នែកមួយនៃដែនឆ្នេរសមុទ្ររបស់រដ្ឋមួយ ហើយបិតនៅក្រោមយុត្តាធិការរបស់រដ្ឋជាម្ចាស់ឆ្នេរសមុទ្រនោះ ។
- *តំបន់តភ្ជាប់៖* គឺជាតំបន់ដែលភ្ជាប់ទៅនឹងដែនសមុទ្រ ដែលរដ្ឋម្ចាស់កម្មសិទ្ធិឆ្នេរសមុទ្រអាចអនុវត្តយុត្តាធិការដើម្បីបង្ការ និងដាក់ទណ្ឌកម្មដល់ការរំលោភច្បាប់ និងបទបញ្ជានៅក្នុងសមុទ្រដែនសមុទ្រខ្លួន ។
- *តំបន់សេដ្ឋកិច្ចផ្តាច់មុខ៖* គឺជាតំបន់សមុទ្រដែលរដ្ឋជាម្ចាស់តែម្នាក់គត់មានសិទ្ធិរុករកធនធានធម្មជាតិទាំងអស់ ។
- *រដ្ឋម្ចាស់កម្មសិទ្ធិឆ្នេរសមុទ្រ៖* គឺជារដ្ឋដែលមានបណ្តោយឆ្នេរ មានសិទ្ធិផ្តាច់មុខក្នុងការរុករកធនធានធម្មជាតិ សិទ្ធិប្រើប្រាស់យុត្តាធិការខ្លួននៅក្នុងដែនសមុទ្រដែលបានកំណត់ទុក ។
- *ផែរដ្ឋ៖* គឺជារដ្ឋដែលមានឆ្នេរសមុទ្រ និងមានយុត្តាធិការលើកំពង់ផែ ។
- *កំពង់ផែសេរី៖* គឺជាកំពង់ផែដែលរដ្ឋជាម្ចាស់បូរណភាពមិនអាច ឬមិនមានបំណងអនុវត្តយុត្តាធិការរបស់ខ្លួន ។
- *ការគ្រប់គ្រងរដ្ឋផែ៖* គឺជាប្រព័ន្ធមួយដែលរដ្ឋបានចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នា ក្នុងការបន្តយុត្តាធិការលើឆ្នេរសមុទ្រ ដើម្បីអនុញ្ញាតិឲ្យធ្វើអធិការកិច្ចកប៉ាល់បរទេសនៅក្នុងផែរបស់ជាតិខ្លួន ។

- *តំបន់គយ៖* គឺជាតំបន់នៅក្នុងផែដែលបានកំណត់សម្រាប់ទុកដាក់ទំនិញពាណិជ្ជ-កម្ម ដែលមិនទាន់បានបានបង់ពន្ធនៅឡើយ ។
- *តំបន់ត្រួតពិនិត្យរបស់គយ៖* គឺជាតំបន់សុវត្ថិភាព និងគ្រប់គ្រងរាល់សកម្មភាពទាំងអស់ត្រូវដោយអាជ្ញាធរគយ ។

## ៤. នរណាជាជនរងគ្រោះ ? កម្មករនេសាទកម្ពុជាដែលត្រូវបានគេជួញដូរទៅ និងមកពីអាហ្វ្រិកខាងត្បូង

**ភេទ អាយុ និងសញ្ជាតិ៖** កម្មករនេសាទកម្ពុជាដែលត្រូវបានគេជួញដូរគឺជាបុរសពេញវ័យ ជនជាតិកម្ពុជា សញ្ជាតិកម្ពុជា។ ពួកគាត់មានអាយុចន្លោះពី ២៤ ទៅដល់ ៥៤ ឆ្នាំ នៅពេលដែលគេជួញដូរ ។

**គ្រួសារ និងស្ថានភាពសេដ្ឋកិច្ច៖** មានបុរសជាច្រើនរៀបការរួចហើយ និងមានកូនជាទូទៅចន្លោះពី ៣ទៅ ៥ នាក់។ បុរសដែលរៀបការរួចទាំងនោះ ភាគច្រើនរស់នៅជាមួយប្រពន្ធ និងកូនៗរបស់ពួកគាត់ ។ បុរសវ័យក្មេងមិនទាន់រៀបការ តែងតែរស់នៅជាមួយឪពុកម្តាយ បងប្អូន និងសាច់ញាតិ។ ពួកគេទាំងអស់គឺជាជនបង្គោលក្នុងការស្វែងរកចំណូលដើម្បីឧបត្ថម្ភជីវភាពដល់សមាជិកក្នុងគ្រួសារខ្លួន ។

**កម្រិតវប្បធម៌៖** បុរសភាគច្រើនបានចូលរៀនត្រឹមតែកម្រិតមូលដ្ឋានប៉ុណ្ណោះ ។ ភាគច្រើនបានចូលរៀនត្រឹមតែថ្នាក់ទី ២ ឬ ទី ៣ប៉ុណ្ណោះ ហើយមិនបានបញ្ចប់បឋមសិក្សាផងទេ (ថ្នាក់ទី ៦) ។ បុរសពីរនាក់ក្នុងចំណោមបុរសទាំងអស់មិនបានចូលរៀនទាល់តែសោះ ដូច្នេះពួកគាត់មិនចេះអាន និងសរសេរអក្សរឡើយ ។

**វគ្គបណ្តុះបណ្តាលជំនាញ និងបទពិសោធន៍ការងារ៖** មានតែបុរសម្នាក់ប៉ុណ្ណោះដែលមានបទពិសោធន៍ក្នុងការនេសាទនៅសមុទ្រ ។ បុរសទាំងអស់ធ្វើការនៅក្នុងវិស័យខុសៗគ្នាមុនពេលគេជ្រើសរើស ។ ជាទូទៅពួកគាត់ជាកម្មករសំណង់ និងកសិកម្ម ។ តម្រូវការដើម្បីជួយផ្គត់ផ្គង់ជីវភាពគ្រួសារជាកត្តារុញច្រានឲ្យបុរសទាំងនោះសម្រេចចិត្តទទួលយក និងស្វែងរកការងារក្រៅប្រទេស។ ជួនកាលដោយសារពាក់ព័ន្ធនឹងសម្ពាធនៃបំណុលធ្វើឲ្យបុរសទាំងនោះងាយធ្លាក់ចូលទៅក្នុងឧបាយកល «បោកបញ្ឆោត» ជាពិសេសការសន្យាផ្តល់នូវប្រាក់ខែច្រើន និងគួរឲ្យទុកចិត្តបាននៅក្រៅប្រទេស ។

**ស្រុកកំណើត:** បុរសទាំងនោះត្រូវបានជ្រើសរើសចេញពីខេត្តផ្សេងៗគ្នាពាសពេញប្រទេសកម្ពុជាដោយរួមមាន: ភ្នំពេញ កំពត ព្រៃវែង សៀមរាប បន្ទាយមានជ័យ កំពង់ឆ្នាំង កំពង់ចាម កំពង់ស្ពឺ ក្រចេះ និងតាកែវ ។

## ៥. ការជ្រើសរើសពលករនេសាទកម្ពុជា តួនាទីរបស់ទីភ្នាក់ងារ Giant Ocean

**ការជ្រើសរើសស្របច្បាប់ និងទីភ្នាក់ងារជ្រើសរើស៖** កម្មករនេសាទកម្ពុជាដែលត្រូវបានគេជ្រើសរើសទៅកាន់អាហ្វ្រិកខាងត្បូងគឺត្រូវបានជ្រើសរើសដោយស្របច្បាប់ ដើម្បីទៅធ្វើការជាកម្មករនេសាទតាមរយៈទីភ្នាក់ងារជ្រើសរើសឈ្មោះ Giant Oceanដែលបានចុះបញ្ជីជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈកម្ពុជា ។ ដំណើរការជ្រើសរើសដោយស្របច្បាប់ តាមរយៈក្រុមហ៊ុនចុះបញ្ជីត្រឹមត្រូវធ្វើឲ្យមនុស្សម្នាផងទាំងពួងគិតថានឹងមានសុវត្ថិភាពគ្រប់គ្រាន់ និងគួរឲ្យទុកចិត្តបាន ។ បុរសជាច្រើនដែលយើងបានសម្ភាសន៍មានទស្សនៈបែបនេះ ។ ពួកគាត់បាននិយាយអំពីអារម្មណ៍ដែលគិតថាភាពស្របច្បាប់នេះហើយដែលពួកគាត់ទុកចិត្តក្រុមហ៊ុនជ្រើសរើសពលករនេះ ។ បុរសជាច្រើនបានចៀសវាង «ការប្រថុយ» ដោយការពាក់ព័ន្ធដំណើរការជ្រើសរើសតាមរយៈមេខ្យល់រកការងារមិនស្របច្បាប់ (ដែលគាត់បានដឹងថាអាចនាំទៅការជួញដូរមនុស្ស) គាត់មិនដែលគិតថាតាមរយៈដំណើរការជ្រើសរើសស្របច្បាប់ និងភាពជឿជាក់លើសុវត្ថិភាពមិនអាចមាននាំគាត់ទៅរកទទួលលទ្ធផលបែបនេះឡើយ ។ បើមើលពីខាងក្រៅ ដំណើរការជ្រើសរើសពលករនេះគឺមានលក្ខណៈស្របច្បាប់ និងផ្លូវការ ប៉ុន្តែធាតុពិតគឺទីភ្នាក់ងារដែលបានចុះបញ្ជីស្របច្បាប់នោះមិនមានអាជ្ញាប័ណ្ណក្នុងការជ្រើសរើសពលករនេសាទនោះឡើយ ។ នេះជាចម្ងល់ដែលបានចោទសួរលើយន្តការត្រួតពិនិត្យ និងតាមដានទីភ្នាក់ងារជ្រើសរើសពលករ និងយន្តការផ្អាកអាជីវកម្មបន្ទាប់ពីរកឃើញថាទីភ្នាក់ងារជ្រើសរើសពលករនោះបានរំលោភលើសារាចរណ៍ណែនាំនោះ ។

**តួនាទីរបស់មេខ្យល់ និងឈ្មួញកណ្តាល៖** បុរសភាគច្រើនបានដឹងអំពីទីភ្នាក់ងារជ្រើសរើសGiant Ocean តាមរយៈមេខ្យល់ ឬឈ្មួញកណ្តាល ដែលមកដល់ភូមិរបស់ពួកគាត់ម្នាក់ៗដើម្បីជ្រើសរើសពលករ ។ បុរសខ្លះបានដឹងអំពីទីភ្នាក់ងារនេះ តាមរយៈមិត្តភក្តិ ឬអ្នកជិតខាង ឬតាមរយៈការផ្សព្វផ្សាយនៅតាមវិទ្យុ និងក្នុងព្រឹត្តិប័ត្រព័ត៌មាន ។ មិនមានបុរសណាម្នាក់បង់កម្រៃសេវាជ្រើសរើសទៅឲ្យមេខ្យល់ ឬទីភ្នាក់ងារជ្រើសរើសពលករនោះទេ ។

**ការសន្យាការងារនៅពេលធ្វើការជ្រើសរើស៖** ស្ទើរគ្រប់ករណីទាំងអស់ (២៧ ករណីក្នុងចំណោម ៣១) បុរសទាំងនោះត្រូវបានទីភ្នាក់ងារជ្រើសរើសប្រាប់ថាពួកគាត់នឹងត្រូវធ្វើការនៅលើកប៉ាល់នេសាទ ។ ប៉ុន្តែ ពួកគាត់មិនបានពន្យល់ច្បាស់លាស់អំពីការងារដែលនឹងតម្រូវឲ្យធ្វើនោះទេ ។ ភាគច្រើននៃបុរសទាំងនោះ (១៧នាក់) ត្រូវបានសន្យាការងារនៅប្រទេសជប៉ុន ។ មានបុរសចំនួន ៦ នាក់ដែលបានដឹងថាពួកគាត់នឹងត្រូវទៅអាហ្វ្រិកខាង

ត្បូង ហើយបុរសផ្សេងទៀតបានដឹងថាពួកគាត់នឹងត្រូវទៅទ្វីបអាហ្វ្រិក ប៉ុន្តែមិនច្បាស់ថាប្រទេសណាទេ ។ បុរសបីនាក់មិនត្រូវបានប្រាប់ពីកន្លែងដែលពួកគាត់នឹងត្រូវបញ្ជូនទៅនោះទេ ។ បុរសម្នាក់ត្រូវបានសន្យាការងារជាកម្មករនេសាទនៅប្រទេសនេប៉ាល់ អ្នកផ្សេងទៀតនៅប្រទេសសឹង្ហបុរី ម្នាក់ទៀតនៅប្រទេសចិន ។

**ការសន្យាប្រាក់ខែ និងអត្ថប្រយោជន៍ផ្សេងទៀត និងលក្ខខណ្ឌការងារ៖** បុរសភាគច្រើនត្រូវបានសន្យាឲ្យប្រាក់ខែ ១៥០ ដុល្លារសហរដ្ឋអាមេរិកក្នុងមួយខែ ដោយមានប្រាក់បន្ថែមសម្រាប់ការងារថែមម៉ោង ឬសម្រាប់ការចាប់បានប្រភេទត្រីពិសេសណាមួយ ។ មានការដាក់ទណ្ឌកម្ម និងផាកពិន័យដែរ ខណៈដែលមានការរំលោភលើកិច្ចសន្យា ឧ. មិនបានបញ្ចប់រយៈពេលកិច្ចសន្យាការងារ ដែលជាទូទៅរវាងពី ២ ទៅ ៣ឆ្នាំ។

**កិច្ចសន្យា និងកិច្ចព្រមព្រៀងការងារ:** បុរសភាគច្រើន (១៥ នាក់ក្នុងចំណោម ៣១) បានចុះហត្ថលេខាលើកិច្ចសន្យា លាយលក្ខណ៍អក្សរជាផ្លូវការជាមួយទីភ្នាក់ងារជ្រើសរើស Giant Ocean ។ ក្នុងករណីខ្លះ បុរសទាំងនោះបានចុះហត្ថលេខាលើកិច្ចសន្យាទាំងពីរភាសា គឺភាសាខ្មែរ និងអង់គ្លេស ហើយយ៉ាងហោចណាស់ ក៏ពួកគាត់បានយល់អំពីលក្ខខណ្ឌដែលបានរៀបរាប់នៅក្នុងច្បាប់ជាភាសាខ្មែរនោះដែរ ។ ករណីខ្លះផ្សេងទៀត កិច្ចសន្យាមិនមានភាសាខ្មែរឡើយ ។ បុរសម្នាក់បានប្រាប់ថា គាត់បានចុះហត្ថលេខាលើកិច្ចសន្យាដែលមានតែជាភាសាអង់គ្លេស និងភាសាចិនប៉ុណ្ណោះ ដែលគាត់មិនអាចអាន និងយល់បាន ។ លើសពីនេះទៀត បុរសមួយចំនួនមិនចេះអក្សរ ឬមានកម្រិតវប្បធម៌ទាប ហើយមិនអាចអាន និងយល់នូវលក្ខខណ្ឌនៃកិច្ចសន្យា ដូច្នេះមិនសំដៅតែលើភាសាមួយមុខទេដែលបង្កឲ្យមិនបានយល់ដឹងពីកិច្ចសន្យានោះ ។ បុរសខ្លះទទួលបាននូវច្បាប់ថតចម្លងនៃកិច្ចសន្យារបស់ខ្លួន ដើម្បីរក្សាទុក ។ ប៉ុន្តែជាទូទៅទីភ្នាក់ងារជ្រើសរើសពលករជាអ្នករក្សាទុកកិច្ចសន្យាការងារនោះបន្ទាប់ពីបានចុះហត្ថលេខារួច ឬដកហូតវាពីបុរសទាំងនោះនៅពេលពួកគាត់ចេញដំណើរទៅធ្វើការក្រៅប្រទេសក្រោមលេស «រក្សាសុវត្ថិភាព» ។ បុរសមួយចំនួនបានត្រឹមតែផ្តល់កិច្ចព្រមព្រៀងផ្ទាល់មាត់ជាមួយទីភ្នាក់ងារជ្រើសរើសប៉ុណ្ណោះ ដោយមិនបានចុះហត្ថលេខាលើកិច្ចសន្យាការងារជាលាយលក្ខណ៍អក្សរឡើយ ។

**តម្លៃនៃដំណើរការជ្រើសរើស និងតម្លៃសេវារបស់ទីភ្នាក់ងារ៖** មិនមានបុរសណាម្នាក់បង់ថ្លៃសេវាជ្រើសរើសទៅទីភ្នាក់ងារឡើយ ។ ផ្ទុយទៅវិញ ទីភ្នាក់ងារបានផ្តល់ដល់បុរសទាំងនោះនូវការបើកប្រាក់ខែមុនក្នុងចំនួន ១០០ ដុល្លារសហរដ្ឋអាមេរិក ។ បុរសពីរនាក់បានខ្ចីប្រាក់មុនពេលចាកចេញ ដើម្បីជួយដល់សមាជិកគ្រួសាររបស់គាត់ ទម្រាំដល់ពេលដែលគាត់ទទួលបានប្រាក់ខែដំបូងរបស់គាត់ពីកន្លែងការងារនៅក្រៅប្រទេស ។ ថ្វីត្បិតតែប្រាក់ដែលបានខ្ចីនោះមានចំនួនតិចតួចយ៉ាងណាក្តីពួកគាត់បាននិយាយថាពួកគាត់មានក្តីព្រួយបារម្ភកាន់តែខ្លាំងឡើងដោយសារបំណុលនោះ ។

**«វគ្គបណ្តុះបណ្តាល» មុនពេលចាកចេញ៖** បុរសមួយចំនួនបានទទួលការណែនាំដល់ពួកគាត់ដែលគេចាត់ទុកជា «វគ្គបណ្តុះបណ្តាលមុនពេលចេញដំណើរ» ដែលផ្តល់ដល់ពួកគាត់នូវជំនាញ ហើយនឹងពង្រឹងកម្លាំងកាយដែលត្រូវការសម្រាប់ការងារនៅលើកប៉ាល់នេសាទ ។ ធាតុពិតវគ្គបណ្តុះបណ្តាលនោះគឺមិនមែនស្តីពីការងារនេសាទនោះទេ ប៉ុន្តែវាផ្តោតទៅលើលំហាត់ប្រាណ និងកសាងកម្លាំងសម្រាប់ការងារ និងជីវិតរស់នៅលើទូកតែប៉ុណ្ណោះ ។ បុរសមួយចំនួនមិនបានទទួលការតម្រង់ទិសអ្វីទាំងអស់ ប៉ុន្តែត្រូវបានដាក់ឲ្យធ្វើការភ្លាមៗបន្ទាប់ពីការជ្រើសរើសរួច ។ វគ្គបណ្តុះបណ្តាលនេះ ទំនងជាការឆ្លៀតពេលក្នុងខណៈពេលដែលទីភ្នាក់ងារជ្រើសរើសពលកររង់ចាំរៀបចំ និងរត់ការឯកសារផ្សេងៗ ឬតម្រូវការពលករពីកប៉ាល់នេសាទតែប៉ុណ្ណោះ ។

**លិខិតឆ្លងដែន ប័ណ្ណការងារ និងសៀវភៅសំគាល់ជាកម្មករនេសាទ៖** ជាទូទៅឯកសារទាំងនេះត្រូវបានរៀបចំឡើងក្នុងកំឡុងពេលបណ្តុះបណ្តាល/ដំណាក់កាលរៀបចំ រួមមានលិខិតឆ្លងដែនអន្តរជាតិ ប័ណ្ណការងារ ទិដ្ឋាការ និង/ឬ សៀវភៅសំគាល់ខ្លួនកម្មករនេសាទ ។ បុរសទាំងអស់ត្រូវធ្វើដំណើរជាមួយលិខិតឆ្លងដែន ។ ពួកគាត់ទទួលបានទិដ្ឋាការមានសុពលភាព និងប័ណ្ណការងារ ប៉ុន្តែមិនបានប្រាប់អំពីព័ត៌មានលំអិតអំពីនីត្យានុកូលភាព និងសុពលភាពនៃឯកសារទាំងនោះទេ ។ ទីភ្នាក់ងារជ្រើសរើសពលករ Giant Ocean បានចេញប័ណ្ណបញ្ជាក់ការងារទៅឲ្យបុរសទាំងនោះដោយបិទស្លាកថាជាប័ណ្ណការងារ ។ ទីភ្នាក់ងារជ្រើសរើសGiant Ocean ក៏បានចេញសៀវភៅសំគាល់ខ្លួនកម្មករនេសាទឲ្យបុរសទាំងនោះផងដែរ ប៉ុន្តែជាទូទៅសៀវភៅនេះ គួរតែត្រូវបានចេញដោយអាជ្ញាធរនាវាចរណ៍នៅក្នុងប្រទេសកំណើត ហើយមិនមែនសម្រាប់កម្មករនេសាទនោះទេ ។ ឯកសារទាំងអម្បាលមានត្រូវបានរៀបចំ និងបង់ថ្លៃដោយទីភ្នាក់ងារជ្រើសរើសពលករ ។ មិនមានបុរសណាម្នាក់បានចូលរួមផ្ទាល់ក្នុងដំណើរការរត់ការឯកសារទាំងនោះទេ ហើយក៏មិនមានអ្នកណាប្រាប់ថាបានបង់ថ្លៃរត់ការឯកសារទាំងនោះដោយខ្លួនឯងផ្ទាល់ដែរ ។

## ៦. ពីប្រទេសកម្ពុជាទៅកាន់អាហ្វ្រិកខាងត្បូង៖ វិធីដែលបុរសទាំងនោះបានឆ្លងកាត់

**មធ្យោបាយធ្វើដំណើរ និងផ្លូវធ្វើដំណើរ:** ការធ្វើដំណើរត្រូវបានរៀបចំ និងបង់ថ្លៃដោយទីភ្នាក់ងារជ្រើសរើសពលករ ។ បុរសទាំងអស់ទទួលបានសំបុត្រយន្តហោះមុនចេញដំណើរនៅឯព្រលានយន្តហោះ ។ មិនមានអ្នកណាម្នាក់បង់ថ្លៃសោហ៊ុយធ្វើដំណើរនេះជាមុនទេ គឺតម្លៃទាំងអស់នេះនឹងត្រូវកាត់ចេញពីប្រាក់ខែដែលគាត់ទទួលបាននៅលើកប៉ាល់នាពេលខាងមុខ ។ ផ្លូវធ្វើដំណើររបស់កម្មករនេសាទកម្ពុជាទៅកាន់អាហ្វ្រិកខាងត្បូងមាន

ភាពខុសៗគ្នា ។ ភាគច្រើននៃបុរសទាំងនោះ (២០នាក់) បានធ្វើដំណើរតាមយន្តហោះទៅកាន់អាហ្វ្រិកខាងត្បូង ដោយចុះចតប្តូរជើងយន្តហោះនៅក្នុងប្រទេសមួយចំនួនដូចជា ប្រទេសថៃ ម៉ាឡេស៊ី UAE (ឌូបៃ) កូរ៉េ និងកាតា (ឌូហា) ។ បុរសខ្លះមិនបានដឹងច្បាស់អំពីផ្លូវធ្វើដំណើរទាំងនោះទេ ដោយក្រុមហ៊ុនមិនបានប្រាប់ ហើយក៏មិនអាចអានសញ្ញាព័ត៌មាន ឬទំនាក់ទំនងជាមួយអាជ្ញាធរ ឬអ្នកផ្សេងទៀតនៅតាមប្រទេសដោយចុះចតនោះឡើយ ។ បុរសពីរនាក់បានធ្វើដំណើរទៅកាន់អាហ្វ្រិកខាងត្បូងតាមយន្តហោះទៅកាន់ប្រទេសសឹង្ហបុរីជាមុន ហើយបន្ទាប់មកចុះតាមនាវាទៅកាន់អាហ្វ្រិកខាងត្បូងតែម្តង ។

**ឯកសារ និងលិខិតអនុញ្ញាតិ ការឆ្លងដែន និងចូលប្រទេស៖** បុរសដែលត្រូវបានគេជួញដូរទៅធ្វើជាកម្មករនេសាទនៅសមុទ្រអាហ្វ្រិកខាងត្បូង បានចូលទៅក្នុងប្រទេសអាហ្វ្រិកខាងត្បូងដោយស្របច្បាប់ ដោយប្រើប្រាស់លិខិតឆ្លងដែនអន្តរជាតិ និងទិដ្ឋាការ ។ បុរសដែលមកតាមរយៈយន្តហោះ ជាទូទៅត្រូវបានគេផ្តល់នូវ «ទិដ្ឋាការនាវិក» បណ្តោះអាសន្ន នៅឯព្រលានយន្តហោះអាហ្វ្រិកខាងត្បូង ដែលអនុញ្ញាតិឲ្យពួកគាត់អាចចូលក្នុងប្រទេស និងចុះកប៉ាល់បាន ។ សម្រាប់បុរសដែលមកតាមរយៈជើងទឹក ទិដ្ឋាការរបស់ពួកគាត់មិនមានលក្ខណៈច្បាស់លាស់នោះទេ ។

**ការមកដល់ និងចុះកប៉ាល់៖** បុរសទាំងអស់ដែលធ្វើដំណើរតាមរយៈយន្តហោះ ជាទូទៅបានជួបជាមួយអ្នកទទួលនៅឯព្រលានយន្តហោះនៅពេលទៅដល់អាហ្វ្រិកខាងត្បូង ហើយអមដំណើរពួកគាត់ទៅកាន់កំពង់ផែ Cape Town ។ អ្នកដែលមកទទួលពួកគាត់មានសញ្ជាតិខុសៗគ្នា ភាគច្រើនចិនដីគោក ឬចិនតៃវ៉ាន់ ប៉ុន្តែក៏មានសញ្ជាតិផ្សេងដែលពួកគេជាតំណាងក្រុមហ៊ុននេសាទប្រចាំនៅឯកំពង់ផែ ។ បុរសខ្លះបានចុះកប៉ាល់ភ្លាមៗនៅពេលដែលពួកគាត់ទៅដល់កំពង់ផែ ហើយចាកចេញពីកំពង់ផែតែម្តង ។ អ្នកផ្សេងទៀតនិយាយថាពួកគាត់បានស្នាក់នៅលើកប៉ាល់ដែលចតនៅកំពង់ផែ Cape Town មួយរយៈ ដើម្បីធ្វើការរៀបចំការងារ និងបណ្តុះបណ្តាលអំពីវិធីនេសាទត្រី ។ បុរសមួយចំនួនត្រូវបានរង់ចាំនៅកំពង់ផែមុនពេលចុះកប៉ាល់ ដោយក្រុមហ៊ុនផ្តល់កន្លែងស្នាក់នៅបណ្តោះអាសន្ននៅក្នុងបន្ទប់នៅកំពង់ផែ ។ បុរសម្នាក់ត្រូវបានគេចាក់សោរទុកក្នុងបន្ទប់នៅឯកំពង់ផែ ដោយមិនអាចចេញទៅណាទាំងអស់ ហើយត្រូវបានឃ្លាំមើលយ៉ាងតឹងរឹងពីកងសន្តិសុខ ។

## ៧. ការកេងប្រវ័ញ្ចនៅសមុទ្រ និងតំបន់ក្រៅដែនទឹក អាហ្វ្រិកខាងត្បូង ៖ បទពិសោធន៍នៃការជួញដូរមនុស្ស

**ប្រទេសគោលដៅ និងការកេងប្រវ័ញ្ច៖** នៅក្នុងការសិក្សានេះ បុរសទាំងអស់ដែលត្រូវបានគេជួញដូរលើកប៉ាល់នេសាទត្រូវគេកេងប្រវ័ញ្ចនៅលើកប៉ាល់នេសាទនៅក្នុងដែនទឹក និងខាងក្រៅសមុទ្រអាហ្វ្រិកខាងត្បូង ។ ទីតាំងជាក់លាក់នៃការនេសាទមិនច្បាស់

លាស់ទេ ប៉ុន្តែអាចនឹងនៅបរិវេណសមុទ្រដែនដីអាហ្វ្រិកខាងត្បូង (ដោយរាប់ទាំងតំបន់ តភ្ជាប់ផងដែរ) តំបន់សេដ្ឋកិច្ចផ្តាច់មុខ និងខ្ពង់រាបបាតសមុទ្រ ឬលំហសមុទ្រហួសពីយុត្តាធិការរបស់អាហ្វ្រិកខាងត្បូង ។ បុរសម្នាក់ដំបូងឡើយត្រូវបានគេកេងប្រវ័ញ្ចនៅក្នុងបរិវេណអាហ្វ្រិកខាងត្បូង ប៉ុន្តែក្រោយមកត្រូវបានចុះកប៉ាល់នេសាទទៅកាន់សមុទ្រប៉ាស៊ីហ្វិកជាកន្លែងដែលគាត់ត្រូវគេកេងប្រវ័ញ្ចសម្រាប់អាជីវកម្មនេសាទផងដែរ ។

**ប្រភេទកប៉ាល់ និងប្រភេទត្រី៖** រាល់ការងារទាំងអស់ទៅនៅលើកប៉ាល់នេសាទដែលអូសមងឆ្ងាយៗ ដោយចំណាយពេលរាប់ខែ រហូតដល់ឆ្នាំនៅឯសមុទ្រ ហើយជារឿយៗធ្វើដំណើរយ៉ាងវែងឆ្ងាយ ។ មិនមានបុរសណាម្នាក់បានដឹងច្បាស់អំពីប្រភេទត្រីជាក់លាក់ដែលកប៉ាល់របស់ខ្លួនចង់បាននោះទេ ប៉ុន្តែតាមរយៈការរៀបរាប់ វាហាក់បីដូចជាភាគច្រើនពួកគាត់ចុះទូកដើម្បីរកចាប់ប្រភេទពួជត្រីធូណា។

**ឈ្មោះកប៉ាល់ និងទង់ជាតិ៖** បុរសប្រហែលជាមួយភាគបីប៉ុណ្ណោះ ដែលអាចចាំឈ្មោះ ឬលេខកប៉ាល់ដែលពួកគាត់ធ្វើការបាន ។ អ្នកផ្សេងទៀតមិនអាចអានឈ្មោះកប៉ាល់នោះ ឬចងចាំឡើយ ។ បុរសខ្លះអាចចាំ និងពណ៌នាអំពីរូបរាងទង់ជាតិនៅលើកប៉ាល់ ជាកន្លែងដែលពួកគាត់ត្រូវគេកេងប្រវ័ញ្ចនោះ ដែលទង់ជាតិទាំងនោះត្រូវបានសំគាល់ថាជារបស់ប្រទេសចិន ខេត្តតៃវ៉ាន់របស់ប្រទេសចិន ជប៉ុន និងអាហ្វ្រិកខាងត្បូង ។ អ្នកបើកនាវាភាគច្រើនគឺមកពីប្រទេសចិន ឬខេត្តតៃវ៉ាន់របស់ប្រទេសចិន។ ចំណែកឯកម្មករលើកប៉ាល់នេសាទជាទូទៅមានចម្រុះជាតិសាសន៍ដែលមកពីប្រទេស ភូមា កម្ពុជា ចិន ហ្វីលីពីន ឥណ្ឌូនេស៊ី ម៉ាឡេស៊ី ខេត្តតៃវ៉ាន់នៃប្រទេសចិន និងវៀតណាម ។

**លក្ខខណ្ឌការងារនៅលើកប៉ាល់៖** គ្រប់បុរសទាំងអស់ត្រូវបានគេកេងប្រវ័ញ្ចនៅលើកប៉ាល់នេសាទឯកណ្តាលមហាសាគរ ធ្វើការច្រើនម៉ោង និងស្ថានភាពដ៏លំបាកលំបិន ។ កម្មករនេសាទកម្ពុជាធ្វើការងារជាច្រើនប្រភេទនៅក្នុងសមុទ្រទាក់ទងនឹងការនេសាទ និងការងារផ្សេងៗទៀតលើទូកនេសាទ ។ ជាទូទៅពួកគាត់ធ្វើការយ៉ាងតិចបំផុត ១៨ម៉ោង ហើយប្រហែលជាពាក់កណ្តាលក្នុងចំណោមបុរសទាំងអស់ធ្វើការរហូតដល់ ២០ម៉ោង ឬច្រើនជាងនេះក្នុងមួយថ្ងៃៗ ។ ពួកគាត់ត្រូវបានគេបង្ខំឲ្យធ្វើការទោះបីជាឈឺ មានរបួស ឬអស់កម្លាំងក៏ដោយ ។ បុរសទាំងនោះក៏ត្រូវតស៊ូផ្លាស់ប្តូរជីវិតរបស់ខ្លួនឯង ឲ្យបត់បែនសម្រាប់ធ្វើការនៅសមុទ្រផងដែរ ឧ. ការពុលរលក អាកាសធាតុអាក្រក់ខ្លាំង រងរបួសដោយប៉ះទង្គិចនឹងឧបករណ៍នៅលើនាវាជាដើម។ ពួកគាត់មានពេលវេលាសម្រាកតែនៅពេលដែលពួកគាត់ចូលចតនៅកំពង់ផែប៉ុណ្ណោះ ដែលវាជារឿងកម្រខ្លាំងណាស់ ។ វាមិនមែនជារឿងចម្លែកទេ ដែលពួកគាត់មួយចំនួនត្រូវបានកេងប្រវ័ញ្ចអស់រយៈពេលច្រើនខែនោះព្រោះកម្មករនេសាទឯទៀតត្រូវគេកេងប្រវ័ញ្ចរហូតដល់ ៣ ឆ្នាំឯណោះ ។ នៅពេលនោះ បុរសទាំងនោះចំណាយពេលយ៉ាងយូរនៅឯសមុទ្រ ដោយកម្រនឹងបានចូលមកជាន់ដីគោកណាស់ ។

**សុខភាព និងសុវត្ថិភាពការងារ៖** កម្មករនេសាទកម្ពុជាបានជួបប្រទះការរងរបួស និងជំងឺជាច្រើនដែលជាលទ្ធផលមកពីការងារលំបាក និងមិនមានសុវត្ថិភាពនៅលើកប៉ាល់ ។ បុរសទាំងនោះរៀបរាប់ថាពួកគាត់តែងតែរងរបួស និងមានជំងឺដោយសារតែលក្ខខណ្ឌការងារមិនល្អ ឬការងារលំបាកខ្លាំងតែម្តង ។ កម្មករនេសាទនៅលើកប៉ាល់អួសមងតែងតែជួបបទពិសោធន៍រងរបួសដៃ ដូចជាត្រូវមុត និងដំបៅពីការចាប់ត្រី ឬដកទម្ពក់ផ្លែសន្ទូចចេញពីមាត់ត្រី ឬដោយសារតែយកដៃ និងម្រាមដៃចាប់ត្រីក្នុងមង ប្រើប្រាស់សម្ភារៈគ្រឿងយន្តគ្មានសុវត្ថិភាពដូចជា សន្ទូចស្រាវមង ដែកខ្វង ប្រដាប់ចិញ្ច្រាំនុយជាដើម ។ ពួកគាត់ក៏ធ្លាក់ខ្លួនឈឺ ឬស្លាប់ជាលិកាដោយសារតែការធ្វើការនៅក្នុងកន្លែងកក/បន្ទប់ក្លាសេផងដែរ ។ កម្មករនេសាទកម្ពុជាដែលត្រូវបានកេងប្រវ័ញ្ចនៅឆ្នេរអាហ្វ្រិកខាងត្បូង ហាក់ដូចជាមិនមានសម្ភារៈ បរិក្ខាសមរម្យសម្រាប់ប្រើប្រាស់ក្នុងការងារនៅលើកប៉ាល់នេសាទទាំងនោះទេ ។ មិនមានអ្នកណាម្នាក់ត្រូវបានផ្តល់ឲ្យនូវឧបករណ៍ចាំបាច់មួយចំនួនដូចជាវ៉ែនតាការពារភ្នែក អាវការពារ ឬគ្រឿងការពារត្រជាក់/សើមឡើយ ។ មិនមានបុរសកម្ពុជាណាម្នាក់ដែលបានបញ្ជូនទៅអាហ្វ្រិកខាងត្បូងបានទទួលនូវអាវពោងសុវត្ថិភាព ឬអាចរកពោងការពារជីវិតឡើយ ខណៈពេលនៅលើកប៉ាល់នេសាទនោះសោះឡើយ ។

**លក្ខខណ្ឌរស់នៅលើកប៉ាល់នេសាទ៖** លក្ខខណ្ឌរស់នៅលើកប៉ាល់នេសាទគឺមិនមានលក្ខណៈស្តង់ដា គ្មានផាសុកភាព គ្មានអនាម័យ និងមិនមានលក្ខណៈជាមនុស្សឡើយ ។ បុរសទាំងនោះបាននិយាយអំពីការធ្លាក់ខ្លួនឈឺ ដោយសារតែកង្វះ (ឬគុណភាពមិនល្អ) អាហារ និងកង្វះទឹកសាប ។ ផ្នែកសម្រាប់ស្នាក់នៅលើកប៉ាល់មានលក្ខណៈចង្អៀត ពេលខ្លះគ្មានចន្លោះសម្រាប់បុរសទាំងនោះគ្រាន់តែទម្រេតខ្លួនទេក៏គ្មានដែរ ។ បុរសមួយចំនួនបានធ្លាក់ខ្លួនឈឺ ដោយសារតែលក្ខខណ្ឌរស់នៅមិនល្អ ថែមទាំងគ្មានអនាម័យសម្រាប់រាងកាយទៀតផង ។ បុរសខ្លះទៀតឈឺដោយសារតែមិនមានអាហារ និងទឹកគ្រប់គ្រាន់ ឬអនាម័យល្អ ។ ទាំងជំងឺ និងរបួសជួនកាលមិនបានព្យាបាលមិនបានសមរម្យ ឬជិតដល់ឡើយ ។

**បទពិសោធន៍នៃការរំលោភបំពាន និងហិង្សានៅលើកប៉ាល់នេសាទ៖** បុរសពីរនាក់ក្នុងចំណោម ៣១ នាក់នៅក្នុងការសិក្សានេះមានបទពិសោធន៍រងការវាយដំលើរាងកាយ និងហិង្សាខណៈពេលត្រូវបានគេជួញដូរនៅលើកប៉ាល់នេសាទនៅក្នុងមហាសមុទ្រជុំវិញ អាហ្វ្រិកខាងត្បូង។ បុរសទាំងនោះបានរៀបរាប់ថាពួកគាត់បានទទួលការបំពានលើរាងកាយ និងវាយដំជាច្រើនលើកច្រើនសារ ដោយការទះតប់ និងការដាល់ ព្រមទាំងការវាយនឹងដំបងឈើ និងដំបងឬស្សី និងការគម្រាមនឹងកាំភ្លើងផងដែរ ។ មូលហេតុនៃការប្រើហិង្សាលើរាងកាយនេះគឺជារឿយៗទាក់ទងនឹងការធ្វើការយឺតយ៉ាវ ឬមិនបានល្អ (យ៉ាងហោចណាស់ត្រឹមការកំណត់របស់នាយនាវា និងមេការចង់បាន) ។ បុរសមួយចំនួនក៏ត្រូវបានវាយដំដោយសារតែងងុយដេក ឬសម្រាកយូរពេក ឬញឹកញាប់ពេក ។ ភាសាក៏ជា

ឧបសគ្គធ្វើឲ្យពួកគាត់មិនអាចយល់នូវការបង្គាត់បង្ហាញ ដែលញ៉ាំងឲ្យកម្មករកម្ពុជាតែងតែរងអំពើហិង្សា ជាទណ្ឌកម្មចំពោះការធ្វើការមិនបានល្អ ។ ករណីខ្លះអំពើហិង្សាហាក់ដូចជាត្រូវបានប្រើប្រាស់ជាមធ្យោបាយត្រួតត្រា និងរក្សាភាពភ័យខ្លាច និងធ្វើឲ្យកម្មករទាំងនោះបាក់ស្បាត ។ ហិង្សាក៏ត្រូវបានប្រើជាទណ្ឌកម្មសម្រាប់អាកប្បកិរិយាមិនសមរម្យផងដែរ ។ អំពើហិង្សាមិនត្រឹមតែត្រូវបានប្រើប្រាស់ដោយនាយនាវា និងមេការដើម្បីទប់ទល់នឹងកម្មករដែលត្រូវគេជួញដូរនោះទេ ប៉ុន្តែវាគឺជាលក្ខណៈសំគាល់ពិសេសនៃជីវិតរស់នៅលើកប៉ាល់នេសាទមួយចំនួន ។ បុរសមួយចំនួនរៀបរាប់ថាអំពើហិង្សា និងការវាយតប់គ្នារវាងកម្មករ និងបរិយាកាសតឹងតែង និងហិង្សា រមែងកើតឡើងញឹកញាប់នៅលើកប៉ាល់ ។

បុរសទាំងនោះបានរៀបរាប់ថាកម្រិតនៃការបំពានផ្លូវចិត្តមានដូចជា ស្រែកដាក់ និងជេរប្រមាថ គម្រាមធ្វើការវាយដំ ហិង្សា និងរហូតដល់សម្លាប់ ។ មិនមានបុរសណាម្នាក់ប្រាប់ថាបានជួបប្រទះការរំលោភបំពានផ្លូវភេទឡើយខណៈពេលដែលត្រូវបានគេកេងប្រវ័ញ្ចនៅលើទូកនេសាទ បើទោះបីជាអ្នកផ្តល់សេវានៅក្នុងប្រទេសកម្ពុជាដែលបានជួយដល់បុរសរងគ្រោះមួយចំនួនតូចបានរាយការណ៍ថាមានការបៀតបៀនកេរ្តិ៍ខ្មាស ខណៈពេលពួកគេត្រូវគេជួញដូរនៅលើទូកនេសាទក្តី ។

**ការបង់ប្រាក់ខែ និងការកាត់យកប្រាក់ឈ្នួល៖** កម្មករនេសាទកម្ពុជាបានបញ្ជូនទៅក្រៅប្រទេសតាមរយៈទីភ្នាក់ងារជ្រើសរើសGiant Ocean ទៅធ្វើការនេសាទនៅឆ្នេរអាហ្វ្រិកខាងត្បូង បានទទួលប្រាក់ឈ្នួលតិចតួច ឬមិនបានទទួលរាប់ខែ និងរហូតដល់ឆ្នាំក៏មាន ។ ដោយសារតែបុរសទាំងនោះត្រូវបានបញ្ជូនទៅលើសមុទ្ររាប់ខែ រហូតដល់រាប់ឆ្នាំ ទើបធ្វើឲ្យពួកគាត់អាចត្រឹមដឹងពីការមិនបានទទួលប្រាក់ឈ្នួលនៅពេលដែលពួកគាត់មកដល់កំពង់ផែបន្ទាប់ពីអស់មួយរយៈមក ។ បុរសខ្លះ (តែមិនមែនទាំងអស់នោះទេ)ទទួលបានប្រាក់បន្តិចបន្តួចពីនាយនាវានៅពេលដែលពួកគាត់ចូលចតនៅកំពង់ផែ («ប្រាក់ហោប៉ៅ») ជាទូទៅប្រហែលពី ៥០ ទៅ ២០០ ដុល្លារ ដែលអាចឲ្យពួកគាត់អាចទិញសម្លៀកបំពាក់ថ្មីៗ និងសម្ភារៈប្រើប្រាស់ ឬទូរស័ព្ទទៅក្រុមគ្រួសារ ។ បុរសមួយចំនួនក៏បានទទួលប្រាក់បន្តិចបន្តួចនៅពេលដែលពួកគាត់បានចាកចេញពីកប៉ាល់ផងដែរ ប្រមាណជា ៥០ ទៅ ៣០០ ដុល្លារ ។

**ការរិតត្បិតសេរីភាពនៃការដើរហើរ និងការប្រើប្រាស់អំណាចត្រួតត្រា:** កម្មករនេសាទកម្ពុជាបានរៀបរាប់អំពីវិធីផ្ទេរផលនេសាទដែលរកបាននៅសមុទ្រ និងការដាក់បន្ថែមនូវសម្ភារៈមួយចំនួនផងដែរពីកប៉ាល់មេមួយ ។ បុរសទាំងនោះត្រូវបានបម្លាស់ទីពីកប៉ាល់មួយទៅកប៉ាល់មួយទៀតនៅឯសមុទ្រ ។ ការធ្វើបែបនេះ គឺដើម្បីធានាថាកម្មករមានជំនាញចាំបាច់មាននៅតាមកប៉ាល់នេសាទទាំងអស់ ។ ប៉ុន្តែវាក៏ទំនងជាមធ្យោបាយក្នុងការត្រួតពិនិត្យបុរសទាំងនោះ បង្ការកុំឲ្យពួកគាត់រត់គេចនៅកំពង់ផែផងដែរ ។ បុរសទាំងនោះបានរស់នៅឯសមុទ្រស្ទើរតែពេញមួយជីវិតដែលត្រូវបានគេជួញដូរ ។ ទោះបីជា

នៅកំពង់ផែ ក៏កម្មករនេសាទកម្ពុជាទាំងនោះជាទូទៅមិនដែលទំនេរទេ ។ ពួកគេតម្រូវឲ្យធ្វើការបន្ត លើកត្រីដាក់ចុះ ជួសជុល និងមើលថែទាំគ្រឿងម៉ាស៊ីនកប៉ាល់ ប៉ះមង និងខ្សែសន្ទូចជាដើម។ ជារឿយៗពួកគាត់ត្រូវបានគេរិតត្បិតសេរីភាពក្នុងការដើរហើរ ហើយបិតនៅក្រោមការឃ្លាំមើល និងត្រួតត្រាជានិច្ច។ មិនមានបុរសណាម្នាក់យកឯកសារទៅតាមខ្លួនឡើយនៅពេលនៅលើកប៉ាល់ ឯកសារទាំងនោះត្រូវបានដកហូតនៅពេលដែលពួកគាត់ទៅដល់កំពង់ផែ ហើយរក្សាទុកនៅនាយនាវា ឬក្រុមហ៊ុននេសាទឯកំពង់ផែ ។

## ៨. ការចាកចេញពីកប៉ាល់៖ ចាកចេញ រត់គេច ជួយសង្គ្រោះ និងដោះលែង

**ចាកចេញ រត់គេច ដោះលែង និងជួយសង្គ្រោះ** កម្មករនេសាទកម្ពុជាអាចចាកចេញពីស្ថានភាពជួញដូររបស់ពួកគាត់នៅពេលដែលកប៉ាល់ចូលចតកំពង់ផែតែប៉ុណ្ណោះ ។ មានតែបុរសម្នាក់ប៉ុណ្ណោះដែលបានរៀបរាប់ថា «ត្រូវបានគេជួយសង្គ្រោះ» ពីស្ថានភាពជួញដូររបស់គាត់ បន្ទាប់ពីគាត់ទូរស័ព្ទទៅផ្ទះសុំគេជួយឲ្យចាកចេញពីកប៉ាល់នោះ ។ ក្នុងករណីផ្សេងទៀត ជាទូទៅជនរងគ្រោះរត់គេច ស្វែងរកជំនួយដើម្បីចាកចេញពីកប៉ាល់/កំពង់ផែ ហើយរកវិធីត្រឡប់ទៅកាន់ផ្ទះវិញដោយខ្លួនឯង ។ នោះកើតឡើងបន្ទាប់ពីពួកគាត់បានទូរស័ព្ទទៅផ្ទះជួបក្រុមគ្រួសាររបស់គាត់ ហើយដឹងថាពួកគេមិនបានទទួលប្រាក់ឈ្នួល រីឯក្រុមហ៊ុនក៏បានបាត់ដំណឹងដែរ ។ កម្មករនេសាទខ្លះបានរត់ចេញពីកប៉ាល់ដោយខ្លួនឯងផ្ទាល់ ឬជាមួយអ្នករួមការងារក្នុងកប៉ាល់នោះមួយចំនួន ។ ករណីខ្លះទៀត បុរសកម្ពុជាបានចាកចេញពីកប៉ាល់ជាក្រុមធំ ។ ឧ. កម្មករក្នុងកប៉ាល់ចំនួនបួនផ្សេងគ្នា ដែលធ្វើការជាមួយគ្នានៅឯសមុទ្របានចាកចេញពីកប៉ាល់ទាំងអស់គ្នា នៅពេលដែលកប៉ាល់ចូលចតនៅកំពង់ផែ ។ ក៏នៅមានករណីមួយចំនួនខ្លះទៀត ដែលកម្មករនេសាទដែលត្រូវបានគេជួញដូរត្រូវបាននាយនាវា«ដោះលែង» ប៉ុន្តែ «ការដោះលែង» នេះ ជាទូទៅកើតឡើងបន្ទាប់ពីពួកគាត់ធ្វើការបាន ២ ទៅ ៣ ឆ្នាំហើយ (ឧ. រយៈពេលបញ្ចប់កិច្ចសន្យា) ហើយបុរសទាំងនោះទទួលបានប្រាក់តិចតួច ឬមិនបានប្រាក់ទាល់តែសោះ ។ ករណីមួយចំនួនទៀត ការដោះលែងបុរសទាំងនោះហាក់ដូចជាជាប់ពាក់ព័ន្ធនឹងអាជ្ញាធរដែនដី ។ ប៉ុន្តែពេលខ្លះវាត្រូវការចំណាយពេលយូរដើម្បីរៀបចំរត់ការឯកសារ និងការធ្វើដំណើរនេះដែរ ។ បើទោះបីជាអាជ្ញាធរតែងតែបានចូលរួមពាក់ព័ន្ធនឹងការចរចារយកឯកសារទាំងនោះត្រឡប់មកវិញក៏ដោយ ក៏វាត្រូវការចំណាយពេលខ្លះដែរ ។

**បញ្ហា និងការប្រឈមនៅពេលចាកចេញពីស្ថានភាពជួញដូរ:** ខណៈពេលដែលបុរសទាំងនោះចាកចេញពីស្ថានភាពកេងប្រវ័ញ្ចរបស់ខ្លួនតាមវិធីផ្សេងៗយ៉ាងណាក៏ដោយ ក៏មានបញ្ហាប្រឈមមួយចំនួនជាទូទៅពួកគាត់បានជួបប្រទះ ដែលធ្វើឲ្យការចាកចេញមាន

លក្ខណៈស្មុគស្មាញ ហើយជាទូទៅរារាំងពួកគាត់ពីការកំណត់អត្តសញ្ញាណ និងទទួលបានជំនួយក្នុងឋានៈជាជនរងគ្រោះដោយអំពើជួញដូរនៅអាហ្វ្រិកខាងត្បូង ។ រឿងរ៉ាវទាំងនោះរួមមាន៖

- *កង្វះការកំណត់អត្តសញ្ញាណ-កម្មករនេសាទដែលត្រូវគេកេងប្រវ័ញ្ចមិនត្រូវបានចាត់ទុកជាជនរងគ្រោះដោយអំពើជួញដូរទេ៖*
  - *កង្វះក្របខណ្ឌគតិយុត្តិនៅអាហ្វ្រិកខាងត្បូង*
  - *អំពើជួញដូរត្រូវបានសន្និដ្ឋានថា ត្រូវឆ្លងកាត់តាមបណ្តាញមិនស្របច្បាប់*
  - *ជនរងគ្រោះដោយអំពើជួញដូរមិនបានដឹងថាខ្លួនត្រូវបានគេជួញដូរនោះទេ និង*
  - *កង្វះការយល់ដឹងអំពីបញ្ហាជួញដូរមនុស្សនៅក្នុងវិស័យនេសាទជាទូទៅ*
- *បញ្ហាឆន្ទៈ និងធនធាន*
- *កង្វះបទពិសោធន៍អន្តរាគមន៍ក្នុងកប៉ាល់នេសាទ*
- *រយៈពេលអន្តរាគមន៍មានកម្រិត គឺនៅពេលដែលកប៉ាល់ចូលចតនៅឯកំពង់ផែ*
- *ភាសា*
- *កម្មករនេសាទដែលត្រូវគេជួញដូរ មិនត្រូវបានជួយគាំទ្រនៅអាហ្វ្រិកខាងត្បូង*
- *ប្រទេសកម្ពុជាមិនមានស្ថានទូតនៅអាហ្វ្រិកខាងត្បូងហើយដំណើរការការិយាធិបតេយ្យពន្យាពេលអន្តរាគមន៍។*

## ៩. តាមផ្លូវទៅកាន់លំនៅដ្ឋានវិញ - ការវិលត្រឡប់ពីការជួញដូរ

**ការត្រឡប់ទៅផ្ទះ៖** កម្មករនេសាទកម្ពុជាដែលត្រូវបានគេជួញដូរ ត្រូវបានគេកេងប្រវ័ញ្ចនៅអាហ្វ្រិកខាងត្បូង បានបង្ហាញពីអារម្មណ៍ធូរស្បើយ និងមានសុភមង្គលយ៉ាងខ្លាំងនៅពេលទីបំផុតពួកគាត់មានសេរីភាពពីស្ថានភាពជួញដូររបស់ពួកគាត់ហើយអាចត្រឡប់ទៅផ្ទះវិញ ។ បុរសជាច្រើនបានរងចាំអស់មួយរយៈនៅកំពង់ផែ Cape Town ដោយមិនច្បាស់ថាពួកគាត់អាចវិលត្រឡប់ទៅផ្ទះវិញ និងដោយរបៀបណានោះទេ ។

បុរសទាំងនោះត្រឡប់មកប្រទេសកម្ពុជាវិញតាមរយៈយន្តហោះ ។ មួយចំនួនធ្វើដំណើរជាក្រុម ដែលជាទូទៅដោយសារពួកគាត់បានចាកចេញពីកប៉ាល់ និងស្វែងរកជំនួយជាមួយគ្នា ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ក៏មានបុរសមួយចំនួន បានធ្វើដំណើរដោយខ្លួនឯងដែរ ។ ដោយសារការវិលត្រឡប់របស់ពួកគាត់វែងឆ្ងាយ អ្នកខ្លះបានចុះចតនៅប្រទេសជាច្រើន ធ្វើឲ្យនឿយហត់ និងធុញទ្រាន់យ៉ាងខ្លាំង។

មិនមានបុរសណាម្នាក់ ត្រូវបានគេទាមទារឲ្យបង់ថ្លៃធ្វើដំណើរត្រឡប់ទៅវិញឡើយ ។ ប៉ុន្តែព័ត៌មានលំអិត និងការរៀបចំផ្សេងៗ ជុំវិញការវិលត្រឡប់របស់កម្មករនេសាទដែលត្រូវគេជួញដូរ ពីប្រទេសអាហ្វ្រិកខាងត្បូងមក មិនមានភាពច្បាស់លាស់ទេ សូម្បីតែបុរសខ្លួនឯងផ្ទាល់ក៏ដោយ ។ ភាគច្រើនបង្ហាញឲ្យឃើញថាក្រុមហ៊ុននេសាទ ប្រហែលជានាយនាវាបានរៀបចំ និងបង់ថ្លៃធ្វើដំណើរត្រឡប់ទៅផ្ទះវិញដល់បុរសទាំងនោះ ។ ប៉ុន្តែ អ្នកខ្លះអាចបានវិលត្រឡប់មកវិញដោយសារការរៀបចំ និងបង់ថ្លៃសោហ៊ុយពីទីភ្នាក់ងារជ្រើសរើស Giant Ocean មុនពេលទីភ្នាក់ងារនេះបានបិទទ្វារផងដែរ ។ អង្គការ IOMនិង/ឬ អង្គការមិនមែនរដ្ឋាភិបាលកម្ពុជាក៏បានជួយអន្តរាគមន៍លើករណីនេះមួយចំនួនធំដែរ ។ ចំណែកឯរាជរដ្ឋាភិបាលកម្ពុជា មិនបានផ្តល់ថវិការជំនួយសម្រាប់ការវិលត្រឡប់មកវិញ ទៅដល់បុរសដែលត្រូវបានគេជួញដូរនៅអាហ្វ្រិកខាងត្បូងឡើយ ។

ភាគច្រើនបុរសទាំងនោះ មិនបានជួបជាមួយអ្នកណាទេនៅពេលដែលពួកគាត់ត្រឡប់មកដល់ប្រទេសកម្ពុជាវិញ ពួកគាត់ធ្វើដំណើរទៅផ្ទះជួបក្រុមគ្រួសារ និងសហគមន៍ដោយខ្លួនឯងផ្ទាល់ ។ មានពីរបីករណីដែរ គឺថាបុរសទាំងនោះបានទៅការិយាល័យទីភ្នាក់ងារជ្រើសរើស Giant Ocean ភ្លាមៗបន្ទាប់ពីមកដល់ប្រទេសកម្ពុជាវិញដើម្បីទៅទារប្រាក់ឈ្នួលរបស់គេ តែក្រុមហ៊ុនបានបិទទៅហើយ ដូច្នេះពួកគាត់មិនដឹងថាត្រូវទៅណាដើម្បីទាមទារយកប្រាក់របស់ពួកគេឡើយ ។

**បញ្ហាប្រឈម និងផលលំបាកក្នុងការវិលត្រឡប់ទៅផ្ទះវិញ:** កម្មករនេសាទកម្ពុជាបានជួបប្រទះបញ្ហាស្របគ្នាមួយចំនួន ពេលវិលត្រឡប់មកពីប្រទេសអាហ្វ្រិកខាងត្បូងទៅកាន់ផ្ទះវិញ ។ បញ្ហាទាំងនោះរួមមាន៖

- *ថ្លៃធ្វើដំណើរត្រឡប់ទៅវិញថ្លៃ*
- *ការពន្យាពេលការវិលត្រឡប់ទៅផ្ទះវិញនាំឲ្យមានអារម្មណ៍តានតឹងផ្លូវចិត្ត ដោយសារការរង់ចាំយូរ*
- *កម្មករនេសាទដែលត្រូវគេជួញដូរមិនបានជួបអ្នកណាម្នាក់ឡើយនៅពេលវិលត្រឡប់មកដល់ប្រទេសកម្ពុជាវិញ*
- *នៅពេលមកដល់ប្រទេសកម្ពុជាវិញ ពួកគាត់មិនត្រូវបានគេកំណត់អត្តសញ្ញាណទេ*
    - *កង្វះការពិនិត្យរកបញ្ហាច្បាស់លាស់នៅច្រកចូលក្នុងប្រទេសកម្ពុជា និង*
    - *ការវិលត្រឡប់ទៅវិញរបស់ជនរងគ្រោះគឺ «មិនផ្លូវការ»*

## ១០. ជីវិតបន្ទាប់ពីការជួញដូរ-ការស្តារ និងសមាហរណកម្មនៅប្រទេសកម្ពុជា

**ការមកដល់ផ្ទះវិញ:** បុរសភាគច្រើនរៀបរាប់ពីអារម្មណ៍រីករាយដែលបានត្រឡប់មកដល់ផ្ទះនៅប្រទេសកម្ពុជាវិញ ។ ក្រុមគ្រួសាររបស់ពួកគាត់ បានស្វះស្វែងរកគាត់អស់មួយរយៈពេលមកហើយតាមរយៈពីរាជរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល ក្នុងគោលបំណងសុំឲ្យពួកគេជួយដល់បុរសទាំងនោះឲ្យបានវិលត្រឡប់មកវិញ ។ គ្រួសារមួយចំនួនមានការព្រួយបារម្ភថាបុរសទាំងនោះបានបាត់បង់ជីវិតទៅហើយ ។

**បញ្ហាប្រឈម និងផលលំបាកក្នុងការស្តារ និងសមាហរណកម្ម៖** ការវិលត្រឡប់មកផ្ទះវិញគឺជាជីវិតផ្អែមល្ហែមសម្រាប់បុរសទាំងនោះ និងក្រុមគ្រួសាររបស់ពួកគាត់ ។ ខណៈពេលកំពុងរីករាយមានអារម្មណ៍ធូរស្បើយពេលបានវិលត្រឡប់មកផ្ទះវិញ តែពួកគាត់ក៏ត្រូវប្រឈមនិងបញ្ហាមួយចំនួន ដែលពួកគាត់បានជួបប្រទះ ដើម្បីស្វែងរកការស្តារពីការកេងប្រវ័ញ្ច និងសមាហរណកម្មទៅក្នុងគ្រួសារ និងសហគមន៍របស់ពួកគាត់វិញផងដែរ ។ បុរសដែលត្រូវបានគេជួញដូរទៅអាហ្វ្រិកខាងត្បូងបានជួបសម្ភាសន៍នៅជំណាក់កាលខុសៗគ្នា បន្ទាប់ពីបានវិលត្រឡប់មកដល់ផ្ទះវិញ ។ អ្នកខ្លះបានវិលត្រឡប់មកដល់ផ្ទះវិញនៅឆ្នាំ ២០១០ និង ២០១១ ប៉ុន្តែភាគច្រើនបានវិលត្រឡប់មកវិញថ្មីៗនេះ ក្នុងឆ្នាំ ២០១២ និង ២០១៣ ។ ករណីមួយចំនួន បុរសខ្លះទើបតែបានវិលត្រឡប់មកផ្ទះវិញ រយៈពេលពីរបីខែថ្មីៗនេះប៉ុណ្ណោះ ។ នេះមានន័យថា ពួកគាត់ស្ថិតនៅក្នុងជំណាក់កាលសមាហរណកម្មខុសៗគ្នា ហើយបានជួបប្រទះបញ្ហាប្រឈម និងផលលំបាកមួយចំនួនខុសៗគ្នាផងដែរ ដែលរួមមាន៖

- *ការត្រឡប់ទៅកាន់ស្ថានភាពសេដ្ឋកិច្ចលំបាកលំបិន៖* បុរសទាំងនោះជាទូទៅបានត្រឡប់ទៅផ្ទះវិញ ទៅកាន់ស្ថានភាពសេដ្ឋកិច្ចលំបាកវិញ ។ ក្រុមគ្រួសាររបស់ពួកគាត់បានតស៊ូយ៉ាងវេទនាកំឡុងពេលគាត់មិននៅ ។ បន្ទាប់មកបុរសទាំងនោះអាចរកការងារធ្វើបាន ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ស្ថានភាពសេដ្ឋកិច្ចរបស់ពួកគាត់មិនទៀងទាត់នៅឡើយ ពេលខ្លះវាដូចពេលមុនដែលគាត់ត្រូវបានគេជួញដូរ ពេលខ្លះវាកាន់តែយ៉ាប់យ៉ឺនទ្វេថែមទៀត ។ ពួកគាត់ភាគច្រើនជាជនបង្គោល និងជាទូទៅរកប្រាក់ចំណូលតែម្នាក់ឯងសម្រាប់គ្រួសារ ។ បុរសពីរនាក់បានប្រឈមនឹងបំណុលយ៉ាងច្រើនមុនពេលចាកចេញទៅក្រៅប្រទេស គឺជាបំណុលដែលចេះកើនច្រើនឡើងៗ ។ ទាំងនេះត្រូវបានក្លាយជាស្ថានភាពកាន់តែលំបាកបន្ទាប់ពីការជួញដូរ ។ មានបុរសដែលត្រូវបានគេកេងប្រវ័ញ្ចនៅក្នុងអាហ្វ្រិកខាងត្បូងជាច្រើន បានធ្វើទេសន្តរប្រវេសន៍សារជាថ្មីជាច្រើនដងរួចមកហើយ ដោយសារស្ថានភាពសេដ្ឋ

កិច្ចដ៏លំបាករបស់ពួកគាត់បង្ខំពួកគាត់ ពេលខ្លះពួកគាត់ទៅកាន់ខេត្តផ្សេងៗទៀតនៃប្រទេសកម្ពុជា ជួនកាលទៅក្រៅប្រទេសថែមទៀតផង ។

- *ការទប់ទល់នឹងផលប៉ះពាល់នៃអំពើជួញដូរ៖* កម្មករនេសាទដែលត្រូវបានគេជួញដូរ បានតស៊ូដើម្បីស្តារឡើងវិញពីបទពិសោធន៍ជួញដូររបស់គាត់ ទាំងរបួសផ្លូវកាយ និងផ្លូវចិត្ត ដែលជាលទ្ធផលនៃការកេងប្រវ័ញ្ចនៅអាហ្វ្រិកខាងត្បូង ។ បុរសម្នាក់ នៅពេលរៀបរាប់ពីបទពិសោធន៍នៅអាហ្វ្រិកខាងត្បូង បានចាត់ទុកវាជា«ការប៉ះទង្គិចផ្លូវកាយ» អ្នកខ្លះទៀតនៅតែបន្តភាពឈឺចាប់ពីរបួសដែលបង្កឡើងដោយអ្នកកេងប្រវ័ញ្ច រួមមានការឈឺក្បាលរ៉ាំរ៉ៃមកពីប្រេះឆ្អឹងលលាដ៏ក្បាល និងឈឺចាប់ដោយសារការបាក់បែកឆ្អឹងដែលមិនបានព្យាបាលត្រឹមត្រូវ ។ ក្រៅពីនេះក៏មានជំងឺផ្សេងៗទៀតបង្កភាពឈឺចាប់ដូចជា កង្វះអាហាររូបត្ថម្ភ ជំងឺសើរស្បែក និងមួម៉ៅក្តៅក្រហាយ និងបញ្ហាសួតជាដើម ។ បុរសទាំងនោះក៏បានរៀបរាប់អំពីប្រតិកម្មផ្លូវចិត្តមួយចំនួន និងផលប៉ះពាល់ចិត្តសង្គម ដែលបណ្តាលមកពីស្ថានភាពជួញដូររបស់ពួកគាត់ផងដែរ ។
- *កង្វះការជួយគាំទ្រដល់បុរសដែលត្រូវគេជួញដូ គេមិនជួយ ឬជួយតិចតួច៖* វាជាភាពកម្រយ៉ាងខ្លាំងសម្រាប់ការជួយគាំទ្រដល់បុរសដែលត្រូវបានគេជួញដូរនៅក្នុងប្រទេសកម្ពុជា ។ មានកម្មវិធី/សេវាកម្មតែពីរទៅបីប៉ុណ្ណោះ ដែលបុរសត្រូវបានគេជួញដូរអាចទទួលយកបាន ភាគច្រើនគឺសម្រាប់កាលៈទេសៈសង្គ្រោះបន្ទាន់ មិនមែនផ្តោតលើសមាហរណកម្មរយៈពេលយូរអង្វែងនោះទេ ។ សេវាកម្មសម្រាប់បុរសមិនសូវជាមានច្រើនទេ ប៉ុន្តែផ្តោតសំខាន់ទៅតាមតំបន់ដែលត្រូវបានជ្រើសរើសសម្រាប់សេវាកម្មទាំងនោះទៀតផង ។ អ្នកផ្តល់សេវាមួយចំនួនបានរៀបរាប់ថាបានផ្តល់សេវាថែរក្សាសុខភាពសង្គ្រោះបន្ទាន់ ពិគ្រោះយោបល់ ជំនាញវិជ្ជាជីវៈ និងជំនួយផ្នែកច្បាប់ ។ បន្ថែមពីលើនេះទៀត ការបែងចែកសេវាកម្មមានភាពលម្អៀងទៅតាមទីតាំងភូមិសាស្ត្រ ដែលតំបន់ខ្លះនៃផ្ទៃប្រទេសកម្ពុជា មិនមានសេវាកម្មណាមួយសម្រាប់បុរសត្រូវបានគេជួញដូរនោះឡើយ ហើយសេវាកម្មប្រភេទខ្លះ (ដូចជាការគាំទ្រចិត្តសង្គម) អាចរកបានតែនៅទីក្រុងភ្នំពេញប៉ុណ្ណោះ ។ បុរសទាំងនោះមានតម្រូវការជំនួយខុសៗគ្នា ប៉ុន្តែទទួលបានតិចតួចរហូតដល់គ្មានតែម្តង ក្រោយពីរងការជួញដូរនោះ បើទោះបីជាពួកគាត់ត្រូវបានគេកំណត់អត្តសញ្ញាណថាជាជនរងគ្រោះដោយអំពើជួញដូរដោយរដ្ឋាភិបាល និង/ឬ អង្គការមិនមែនរដ្ឋាភិបាល/អន្តរ

ជាតិក៏ដោយ ។ បុរសមួយចំនួនប្រាប់ថាគាត់បានស្នើសុំជំនួយតែមិនទាន់ទទួលបាននៅឡើយទេ ។

- *សេវាផ្តល់ជំនួយមិនត្រូវតាមស្ថានភាពជីវិតរបស់ពួកគាត់ - ជំនួយមិនត្រូវតាមតម្រូវការរបស់ពួកគាត់៖* ជំនួយដែលអាចរកបាន មិនមែនតែងតែសុទ្ធតែត្រូវតាមអ្វីដែលបុរសត្រូវបានគេជួញដូរចង់បាននោះឡើយ ។ បុរសមួយចំនួនបានរៀបរាប់ថាចង់រៀនជំនាញវិជ្ជាជីវៈ ប៉ុន្តែត្រូវប្រឈមនឹងឧបសគ្គផ្ទាល់ខ្លួន និងបច្ចេកទេសមួយចំនួនដែលរារាំងពួកគាត់ពីការទទួលផលពីសេវាកម្មនេះ ។ ជាទូទៅដោយសារតែពួកគាត់ត្រូវជួយផ្គត់ផ្គង់គ្រួសាររបស់គាត់ ហើយមិនអាចលៃលកពេលវេលាទៅរកប្រាក់ចំណូលបានទេនៅពេលពួកគាត់ទៅរៀនជំនាញនោះ ។ សូម្បីតែជំនួយអាចរកបាន ប៉ុន្តែវាមិនមែនតែងតែសមស្របសម្រាប់កម្មករនេសាទដែលត្រូវបានគេជួញដូរអាចធ្វើនោះទេ ហើយឱកាសការងារ និងអាជីវកម្មនៅក្នុងសហគមន៍ដែលបុរសទាំងនោះរស់នៅក៏មានកម្រិតផងដែរ ។ ប្រភេទនៃជំនួយខ្លះក៏លំបាកទទួលយកដោយសារតែមូលហេតុមិនមានភាពងាយស្រួយសម្រាប់ពួកគេ ។ សម្រាប់សេវាកម្មសុខាភិបាល និងពិគ្រោះយោបល់ជាទូទៅមាននៅក្នុងទីក្រុង និងនៅតាមទីរួមខេត្តធំៗ ហើយកន្លែងទាំងនោះភាគច្រើនមិនមែនជាកន្លែងដែលបុរសត្រូវបានគេជួញដូររស់នៅបន្ទាប់ពីការជួញដូរនោះឡើយ ។ ទាំងនេះមានន័យថាការធ្វើដំណើរទៅទទួលយកសេវាទាំងនោះ គឺត្រូវចំណាយលុយសម្រាប់ការធ្វើដំណើរ ហើយកាលណាធ្វើដំណើរទៅនោះនឹងមិនបានទៅធ្វើការងារទេ ប្រសិនបើមិនបានទៅធ្វើការងារទេនោះនឹងមិនមានចំណូលសម្រាប់គ្រួសារដែរ ។
- *ការជួបជុំជាមួយក្រុមគ្រួសារ(ឡើងវិញ) - ការមកដល់ផ្ទះវិញ៖* បុរសភាគច្រើនបានត្រឡប់មករួបរួមជាមួយក្រុមគ្រួសារឡើងវិញបន្ទាប់ពីការកេងប្រវ័ញ្ចនៅឯសមុទ្រ ហើយបានត្រឡប់មករស់នៅក្នុងផ្ទះរបស់ពួកគាត់ និងសហគមន៍ឡើងវិញ ។ ប៉ុន្តែជួនកាលការបែករយៈពេលយ៉ាងយូរ មានន័យថាបុរសទាំងនោះបានវិលត្រឡប់ទៅផ្ទះដើម្បីស្វែងរកគ្រួសារ «បែកបាក់» របស់គាត់វិញ ប្រពន្ធ និងកូនៗរបស់គាត់បានផ្លាស់ប្តូរជីវិតរស់នៅរបស់ពួកគាត់កំឡុងពេលអវត្តមានរបស់គាត់ ។ ការវិលត្រឡប់ទៅផ្ទះវិញមិនមែនជារឿងងាយស្រួលនោះទេ ហើយកម្មករនេសាទដែលត្រូវគេជួញដូរបានជួបប្រទះបញ្ហា និងភាពតឹងតែង សូម្បីតែបានជួបជុំជាមួយក្រុមគ្រួសារហើយក្តី ។ ភាពតឹងតែងមានសភាពខុសគ្នាពីគ្រួសារមួយទៅមួយ ពួកគាត់ភាគច្រើនត្រូវប្រឈមមុខជុំវិញបញ្ហានៃការរំពឹងទុករបស់គ្រួសារ ហើយនឹងប្រតិកម្មតប

ចំពោះការធ្វើទេសន្តរប្រវេសន៍ (មិនជោគជ័យ)របស់បុរសទាំងនោះ ។ ធាតុពិត បុរសមួយចំនួនមិនបានវិលត្រឡប់ទៅផ្ទះវិញភ្លាមទេ បន្ទាប់ពីបានរត់គេចចេញពីការជួញដូរ ដោយជ្រើសរើសធ្វើការនៅលើទូកផ្សេងទៀតជំនួសវិញ ដោយសង្ឃឹមថានឹងអាចរកប្រាក់ខ្លះសម្រាប់វិលត្រឡប់ទៅផ្ទះវិញ ។ ក្រុមគ្រួសារបុរសទាំងនោះមិនមែនសុទ្ធតែបានដឹងរឿងរ៉ាវឈឺចាប់ទាំងឡាយ ដែលបានកើតឡើងចំពោះបុរសនេសាទទាំងនោះទេ ហើយវាក៏មិនមែនជាពេលវេលាល្អបំផុតក្នុងការបញ្ជាក់ និងលើកសរសើរពីភាពលំបាកដែលបុរសនោះបានជួបប្រទះក្នុងន័យត្រូវគេកេងប្រវ័ញ្ចនោះឡើយ ។ វាត្រូវការពេលដើម្បីចងក្រងមនោសញ្ចេតនាក្នុងគ្រួសារ ជាពិសេសរវាងប្តីប្រពន្ធដែលបានរស់នៅបែកគ្នាយ៉ាងយូរ ហើយអាចនឹងមានភាពអាក់អន់ចិត្តជាពិសេសនៅពេលដែលមិនបានដឹងរឿងរ៉ាវដែលបានកើតឡើងនោះ ។ ប៉ុន្តែនេះគឺជាបញ្ហាសម្រាប់សមាជិកគ្រួសារទាំងអស់ មិនមែនតែក្មេងៗនោះទេ ។ ករណីមួយចំនួន ក្នុងការគិតរបស់កុមារ គឺគេក៏មានប្រតិកម្មតបលំបាកចំពោះឪពុករបស់ពួកគេដែលបានទុកគេចោល ។

- *ការធ្វើសមាហរណកម្មទៅកាន់សហគមន៍វិញ - ភាពអាណិតអាសូរ និងការគាំទ្រ ការស្តីបន្ទោស និងភាពអាម៉ាស់៖* នៅពេលដែលសួរពីការស្វាគមន៍នៅក្នុងសហគមន៍របស់ពួកគាត់បន្ទាប់ពីការវិលត្រឡប់ទៅវិញ បុរសមួយចំនួនបានរៀបរាប់ថាពួកគាត់ទទួលបានការរាក់ទាក់ និងកក់ក្តៅពីសមាជិកសហគមន៍របស់ពួកគាត់ ។ ប៉ុន្តែអ្នកផ្សេងទៀតបានតស៊ូជាមួយប្រតិកម្មតបរបស់សហគមន៍គាត់ ដោយខ្មាស់គេពីបទពិសោធន៍រងការជួញដូររបស់ពួកគាត់ ។ អារម្មណ៍នេះទំនងជាមានភាពជាប់ទាក់ទងយ៉ាងច្រើនទៅនឹងបរាជ័យក្នុងការវិលត្រឡប់ទៅផ្ទះដោយគ្មានប្រាប់មកជាមួយ នៅពេលដែលក្លាយខ្លួនជាពលករទេសន្តរប្រវេសន៍បរាជ័យ ។ បុរសជាច្រើនមានភាពលំបាកក្នុងការវិលត្រឡប់ទៅផ្ទះវិញដោយបាតដៃទទេ ។ វាប្រហែលជាដោយសារតាមវប្បធម៌ ដែលបានចែងនៅក្នុងក្រមច្បាប់សង្គម ក្នុងនាមជាបុរសគួរតែអាចមើលថែខ្លួនឯងបាន និងជួយផ្គត់ផ្គង់គ្រួសារ ដោយមិនគួរធ្វើឲ្យបរាជ័យបែបនោះទេ។
- *បញ្ហានៅក្នុងដំណើរការផ្លូវច្បាប់ -តម្រូវការទាមទារសំណង៖* ជំនួយសំខាន់សម្រាប់បុរសដែលត្រូវបានគេជួញដូរ បន្ទាប់ពីការវិលត្រឡប់ទៅកាន់ប្រទេសកម្ពុជាវិញនោះគឺជួយដាក់ពាក្យបណ្តឹងទីភ្នាក់ងារជ្រើសរើសពលករ ។ បុរសជាច្រើនបានទទួលយកជំនួយនេះ ខណៈពេលដែលបុរសទាំងនោះនិយាយអំពីបំណងចង់ទទួលបានយុត្តិធម៌ និងចង់ឲ្យអ្នកធ្វើការជ្រើសរើសនោះទទួលខុសត្រូវ ភាគច្រើន

ពួកគាត់ចាប់អារម្មណ៍ដំបូងនៅក្នុងផ្លូវច្បាប់ដែលជាយន្តការដើម្បីទទួលបានប្រាក់ខែដែលពួកគាត់មិនទាន់ទទួលបាននោះត្រឡប់មកវិញ (ឬសំណងសម្រាប់ការដែលមិនបានទទួលបានប្រាក់ខែ) ។ កាលពីថ្ងៃ ២៩ ខែមេសា ឆ្នាំ២០១៤ ប្រធានទីភ្នាក់ងារជ្រើសរើសពលករ Giant Ocean ត្រូវបានចោទប្រកាន់ពីបទជួញដូរមនុស្ស ប៉ុន្តែមុនពេលដំណើរការករណីនេះ គឺវាបានចំណាយពេលយ៉ាងយូរ និងស្មុគស្មាញដោយរួមមានទាំងបញ្ហាដូចជាដំណើរការស៊ើបអង្កេតយឺតយ៉ាវ សវនាការតែងតែត្រូវពន្យាពេល មិនបានចាប់ខ្លួនជនជាតិកម្ពុជាផ្សេងទៀតដែលបានជាប់ពាក់ព័ន្ធនឹងការកេងប្រវ័ញ្ចបុរសទាំងនោះ ធ្វើឲ្យបុរសទាំងនោះមានអារម្មណ៍តានតឹងផ្លូវចិត្ត ហើយត្រូវចំណាយសោហ៊ុយផ្ទាល់ខ្លួនក្នុងការដើរតួជាជនរងគ្រោះ/សាក្សីជាដើម ។

## ១១. សេចក្តីសន្និដ្ឋាន និងអនុសាសន៍

ខណៈពេលដែលការជួញដូរកម្មករនេសាទកម្ពុជាមិនមែនជារឿងថ្មីទេ ការជ្រើសរើស និងការដឹកជញ្ជូនកម្មករនេសាទតាមរយៈទីភ្នាក់ងារជ្រើសរើសពលករ ដែលបានចុះឈ្មោះស្របច្បាប់ និងដោយមានឯកសារស្របច្បាប់ និងលិខិតអនុញ្ញាតិការងារផងនោះ បានក្លាយជាទំលាប់ប្រតិបត្តិពីប្រទេសកម្ពុជា និងដែលមានប្រសិទ្ធិភាពម្យាងនោះគឺបិទបាំងចេតនាកេងប្រវ័ញ្ច និងជួញដូរបុរសទាំងនោះ ។ បុរសកម្ពុជារាប់រយនាក់បានធ្វើទេសន្តរប្រវេសន៍ការងារក្នុងឧស្សាហកម្មនេសាទ ហើយទីបំផុតត្រូវបានគេជួញដូរ និងកេងប្រវ័ញ្ចនៅលើកប៉ាល់នេសាទ ដែលបានប្រតិបត្តិការនៅតាមបណ្តោយតំបន់ឆ្នេរអាហ្វ្រិកខាងត្បូង ក៏ដូចជានៅតាមតំបន់គោលដៅនៃមហាសមុទ្រអាហ្វ្រិក និងប៉ាស៊ីហ្វិកផ្សេងៗទៀតផងដែរ ។ នេះគឺជាការឆ្លុះបញ្ចាំងពីតម្រូវការយកចិត្តទុកដាក់យ៉ាងប្រុងប្រយ័ត្នទៅលើការជ្រើសរើសពលករ និងការធ្វើទេសន្តរប្រវេសន៍តាមរយៈប្រព័ន្ធរៀបរយ និងស្របច្បាប់ពីប្រទេសកម្ពុជាដោយសារតែឱកាសបំពានច្បាប់នេះនៅតែអាចកើតមាននៅក្នុងប្រទេសកម្ពុជា ។ វាក៏រំលេចឲ្យឃើញម្តងទៀតអំពីគ្រោះថ្នាក់នៃអំពើជួញដូរនៅក្នុងឧស្សាហកម្មនេសាទ មិនត្រឹមតែក្នុងតំបន់អាស៊ីអាគ្នេយ៍ ប៉ុន្តែនៅតាមតំបន់ភូមិភាគនានានៅលើពិភពលោកផងដែរ ។ ការសិក្សានេះក៏ធ្វើឡើងដើម្បីបង្ហាញពីប្រទេសអាហ្វ្រិកខាងត្បូង ដែលជាប្រទេសគោលដៅសម្រាប់ការជួញដូរកម្លាំងពលកម្ម ជាពិសេសនៅក្នុងវិស័យអាជីវកម្មនេសាទ ដែលជាទម្រង់ថ្មីមួយនៃការជួញដូរដែលមានការទទួលស្គាល់ និងមានលក្ខណៈផ្លូវច្បាប់សម្រាប់ប្រទេស ។

វាជារឿងសំខាន់ក្នុងការចងក្រងឯកសារស្តីពីវិធីដែលអំពើជួញដូរកើតឡើងចំពោះករណីទាំងនោះគឺការចងក្រងរបៀបដែលជនត្រូវបានគេជួញដូរត្រូវបាន (និងមិនបាន) កំណត់អត្តសញ្ញាណ និងការជួយឧបត្ថម្ភ (មូលហេតុ) ។ កម្មករនេសាទដែលត្រូវបានគេ

ជួញដូរបានជួបប្រទះបញ្ហា និងឧបសគ្គជាច្រើនទាំងនៅប្រទេសអាហ្វ្រិកខាងត្បូង និងកម្ពុជានៅពេលរត់គេចពីស្ថានភាពរំលោភបំពាន ការរិះរកវិធីត្រឡប់មកផ្ទះវិញ និងការស្តារសម្បទារបស់ខ្លួនឡើងវិញបន្ទាប់ពីរងការកេងប្រវ័ញ្ច និងការជួញដូរ ។ ក្នុងករណីមួយចំនួនភាពខ្វះចន្លោះ និងបរាជ័យក្នុងការឆ្លើយតបចំពោះការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅអាហ្វ្រិកខាងត្បូង បាននាំឲ្យកម្មករនេសាទដែលរងការជួញដូរមិនត្រូវបានគេកំណត់អត្តសញ្ញាណ ហើយត្រូវចាប់បញ្ជូនត្រឡប់ទៅសមុទ្រវិញ និងបន្តរងការឈឺចាប់ពីការកេងប្រវ័ញ្ចនៅលើកប៉ាល់នេសាទអស់រយៈពេលរាប់ខែរហូតដល់រាប់ឆ្នាំបន្តទៀត ។ ករណីខ្លះទៀត បុរសមួយចំនួននៅតែបន្តរស់នៅលើកប៉ាល់ និងក្នុងដៃរបស់អ្នកកេងប្រវ័ញ្ច កំឡុងពេលស្ថានភាពរបស់ពួកគាត់ត្រូវបានគេរៀបចំធ្វើការប៉ាន់ប្រមាណ និងបញ្ជូនត្រឡប់ទៅវិញហើយក៏ដោយ ។ ចំណែកឯមួយចំនួនដែលបានត្រឡប់ទៅផ្ទះវិញហើយក្តី ក៏ខ្វះខាតការជួយគាំទ្រ និងសេវាកម្ម ដែលទោះជាតាមផ្លូវច្បាប់គឺពួកគាត់ជាជនរងគ្រោះដោយអំពើជួញដូរមនុស្សក៏ដោយ ហើយតែងតែប្រឈមមុខនឹងការរកវិធីស្តារលទ្ធភាពខ្លួនឯងឲ្យប្រសើរ និងអាចរើបម្រះចេញពីការជួញដូរមនុស្សនេះ ។

អនុសាសន៍ខាងក្រោមនេះមានគោលបំណងបង្ហាញយ៉ាងច្បាស់សម្រាប់រដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល អង្គការអន្តរជាតិ សហជីព និងសមាគមន៍ និងអ្នកពាក់ព័ន្ធក្នុងស្រុក ដើម្បីធ្វើការឆ្លើយតបទៅនឹងការជួញដូរកម្មករនេសាទកម្ពុជា ។ អនុសាសន៍ទាំងនេះត្រូវបានបង្កើតឡើងជុំវិញវិធីសាស្រ្ត «Ps » នៃការប្រឹងប្រែងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស៖ ការបង្ការទប់ស្កាត់ កិច្ចការពារ ការផ្តន្ទាទោស និងភាពជាដៃគូ។

## ១) ការបង្ការទប់ស្កាត់

ក. ពង្រឹងការចុះត្រួតពិនិត្យទីភ្នាក់ងារជ្រើសរើសពលករ

ខ. រដ្ឋាភិបាលគួរតែពង្រឹងប្រព័ន្ធព័ត៌មានដែលមានស្រាប់សម្រាប់កម្មករនេសាទនៅឯទីភ្នាក់ងារជ្រើសរើសពលករ

គ. ម្ចាស់នាវា និងក្រុមហ៊ុននេសាទ គួរតែធានានូវការជ្រើសរើសកម្មករប្រកបដោយក្រមសីលធម៌

ឃ. អនុវត្តគោលនយោបាយ និងច្បាប់ដែលមានស្រាប់ស្តីពីការជ្រើសរើសតាមប្រព័ន្ធរៀបរយ/ស្របច្បាប់

ង. បង្កើតគោលនយោបាយឲ្យបានច្បាស់លាស់ស្តីពីការជ្រើសរើសកម្មករនេសាទទេសន្តរប្រវេសន៍ដែលមានដំណើរការសមរម្យ និងកិច្ចការពារគ្រប់គ្រាន់

ច. ផ្តល់សច្ចាប័នអនុសញ្ញាអង្គការ ILO (លេខ ៩ និងលេខ ១៧៩) ស្តីពីការគ្រប់គ្រងទីភ្នាក់ងារជ្រើសរើសពលករ និងរកការងារឲ្យធ្វើ

ឆ. ផ្តល់សច្ចាប័នអនុសញ្ញា WIF និងធ្វើឲ្យអនុសញ្ញាចូលជាធរមាន
ជ. ចុះត្រួតពិនិត្យការផ្សព្វផ្សាយពាណិជ្ជកម្មការងារ ឲ្យមានលក្ខណៈអាចទុកចិត្តបាន និងមានស្របច្បាប់
ឈ. បង្កើនការយល់ដឹងអំពីគ្រោះថ្នាក់នៃអំពើជួញដូរតាមរយៈទីភ្នាក់ងារកម្មករដែលបានចុះឈ្មោះស្របច្បាប់
ញ. ផ្តល់ព័ត៌មាន និងប្រភពឲ្យបានច្បាស់លាស់ដើម្បីអាចឲ្យកម្មករនេសាទអាចពិនិត្យមើលការដាក់ពាក្យសុំការងារធ្វើ ។

## ២. កិច្ចការពារ

### ២.១. ការកំណត់អត្តសញ្ញាណ

ក. កែលំអការកំណត់អត្តសញ្ញាណកម្មករនាវា និងកម្មករនេសាទដែលត្រូវបានគេជួញដូរ
ខ. ធ្វើការត្រួតពិនិត្យរកបញ្ហាជួញដូរមនុស្សនៅក្នុងឧស្សាហកម្មនេសាទ
គ. បង្កើតពិធីសារដើម្បីអន្តរាគមន៍នៅក្នុងឧស្សាហកម្មដែលមានការជួញដូរមនុស្ស
ឃ. ពង្រឹងសមត្ថភាពរបស់មន្ត្រីជួរមុខក្នុងការកំណត់អត្តសញ្ញាណកម្មករនេសាទដែលត្រូវបានគេជួញដូរ
ង. ពង្រឹងតួនាទីស្ថានទូត និងកុងស៊ុលក្នុងការកំណត់អត្តសញ្ញាណកម្មករនេសាទដែលត្រូវគេជួញដូរ
ច. ធានាថាកម្មករនេសាទទទួលបានព័ត៌មានសម្រាប់ទំនាក់ទំនងសុំជំនួយក្នុងកប៉ាល់ និងមធ្យោបាយនៃការធ្វើទំនាក់ទំនង
ឆ. យកជនដែលត្រូវសង្ស័យថាជាជនរងគ្រោះដោយអំពើជួញដូរចេញពីស្ថានភាពជួញដូរមនុស្សជាបន្ទាន់
ជ. ដោះស្រាយបញ្ហាភាសាក្នុងការកំណត់អត្តសញ្ញាណជនរងគ្រោះ
ឈ. ដោះស្រាយបញ្ហាខ្វែងគំនិតគ្នាក្នុងការកំណត់អត្តសញ្ញាណជនរងគ្រោះ ។

### ២.២. ការផ្តល់ជំនួយ

ក. កែលំអដំណើរការបញ្ជូនត្រឡប់មកវិញនូវជនរងគ្រោះរបស់រដ្ឋាភិបាលក្នុងឲ្យកាន់តែប្រសើរឡើង និងឆាប់រហ័ស
ខ. ធានានូវការផ្តល់ជំនួយសមរម្យទៅដល់ជនរងគ្រោះដោយអំពើជួញដូរជាបុរសនៅក្នុងប្រទេសកម្ពុជា និងនៅអាហ្វ្រិកខាងត្បូង

គ. ពង្រឹងសមត្ថភាពអ្នកផ្តល់សេវាដែលធ្វើការជាមួយជនរងគ្រោះដោយអំពើជួញដូរមនុស្សជាបុរស
ឃ. សហការជាមួយអ្នកផ្តល់សេវាដែលធ្វើការជាមួយកម្មករនេសាទ
ង. សម្របសម្រួលករណីដើម្បីធានានូវការផ្តល់ជំនួយបានទូលំទូលាយទៅដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស
ច. បង្កើតមូលនិធិផ្តល់ជំនួយសម្រាប់កម្មករតាមសមុទ្រ និងកម្មករនេសាទ
ឆ. ចំណាយសម្រាប់ជំនួយ ជាបន្ទុករបស់រដ្ឋដែលផ្តល់ទង់ជាតិឲ្យនាវា ។

## ៣. ការផ្តន្ទាទោស

ក. ផ្តន្ទាទោសទីភ្នាក់ងារជ្រើសរើសពលករ ដែលបញ្ជូនកម្មករទៅធ្វើការក្នុងកប៉ាល់ដែលពួកគាត់រងការកេងប្រវ័ញ្ច
ខ. ផ្តន្ទាទោសក្រុមហ៊ុននេសាទដែលបានផលចំណេញពីការកេងប្រវ័ញ្ចកម្មករនេសាទ
គ. បង្កើតប្រព័ន្ធសហប្រតិបត្តិការឆ្លងដែនសម្រាប់មន្ត្រីអនុវត្តច្បាប់ និងការផ្តន្ទាទោសនៃអំពើជួញដូរមនុស្ស
ឃ. ធានាថាសាក្សី និងជនរងគ្រោះអាចចូលរួមផ្តល់សក្ខីកម្មដាក់បន្ទុកបាន
ង. អនុវត្តការទទួលខុសត្រូវតាមផ្លូវច្បាប់របស់រដ្ឋដែលបានផ្តល់ទង់ជាតិ
ច. បន្តដំណើរការករណីជួញដូរកម្លាំងពលកម្ម រួមទាំងករណីនេសាទផងដែរ
ឆ. សហការជាមួយមេធាវីជើងទឹកដើម្បីផ្តល់ជំនួយដល់ជនរងគ្រោះដែលរងការរំលោភបំពាន និងកម្មករនេសាទដែលគេបោះបង់ចោល
ជ. កែលំអខ្លឹមសារច្បាប់ដោយបញ្ចូលបន្ថែមអំពើហឹង្សាកើតមាននៅក្នុងឧស្សាហកម្មនេសាទ
ឈ. ស្វែងរកគ្រប់វិធីទាំងអស់ ដើម្បីទាមទាររកសំណងជូនកម្មករនេសាទវិញ ។

## ៤. ភាពជាដៃគូ

ក. បង្កើតពិធីសារ និងដំណើរការដើម្បីចែករំលែកទិន្នន័យអំពីការរំលោភបំពានឲ្យមានសុវត្ថិភាព និងរក្សាការសំងាត់
ខ. បង្កើតយន្តការបញ្ជូនបន្តរវាងអាហ្វ្រិកខាងត្បូង និងប្រទេសកម្ពុជាដើម្បីសម្របសម្រួលការកំណត់អត្តសញ្ញាណ និងមាតុភូមិនិវត្តន៍កម្មករនេសាទដែលត្រូវបានគេជួញដូរ
គ. បង្កើតទំនាក់ទំនងរវាងក្រុមការងារពាក់ព័ន្ធប្រយុទ្ធប្រឆាំងអំពើជួញដូរ និងក្រុមការងារដែលធ្វើការដើម្បីជួយដល់កម្មករនេសាទ

ឃ. ធ្វើការតស៊ូមតិក្នុងការផ្តល់ទង់ជាតិ FoCs និងទង់ជាតិមិនអនុវត្តតាម FoNCs ដើម្បីពង្រឹងការឆ្លើយតបការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

ង. ពង្រឹងការយកចិត្តទុកដាក់ និងដាក់សម្ពាធដល់ការជួញដូរនៅសមុទ្រតាមរយៈរបាយការណ៍អំពើការជួញដូរមនុស្សរបស់សហរដ្ឋអាមេរិក។